ហួត សេងគៀ

# ជម្រើសទីពីរ



១០សំណួរទាក់ទងនឹងសៀវភៅអេឡិចត្រូនិច

ទំព័រដើម

តើ eBooks ជាអ្វី?

តើ eBooks មានគុណសម្បត្តិអ្វីខ្លះ?

តើ eBooks គួរតែមានតម្លៃប៉ុន្មាន?

តើអ្នកណាខ្លះដែលគួរអាន eBooks?

តើអ្នកណាដែលអាច
បង្កើត eBooks?

តើនៅពេលណាខ្លះដែលអ្នកនិពន្ធដាក់ eBooks ឱ្យគេ
អាន free?

តើខ្ញុំគួរចំណាយលុយទិញ Kindle ដើម្បីអាន eBooks ដែរ
ទេ?

តើរដ្ឋាភិបាល មានជួយគាំទ្រការអានដែរទេ?

តើអ្នកអានគួរគាំទ្ររោងពុម្ព ឬគាំទ្រអ្នកនិពន្ធ?

ទំព័រចុងក្រោយ

អំពីអ្នកនិពន្ធ

# ទំព័រដើម

រឿងមួយដែលខ្ញុំដឹងដោយ គឺកាន់តែសរសេរសៀវភៅបានច្រើន យើងកាន់តែមានអ្វីត្រូវសរសេរបន្តទៀត។ ការសរសេរសៀវភៅសម្រាប់ខ្ញុំ ប្រៀបដូចជាអ្នកធ្វើការរដ្ឋ ដែលត្រូវធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយ ទម្រាំដល់ពេលចូលនិវត្តន៍។ គ្រាន់តែផ្លូវធ្វើដំណើររបស់ខ្ញុំ មិនសូវមានភាពធុញទ្រាន់ និងមិនចាំបាច់មើលទឹកមុខអ្នកដទៃប៉ុណ្ណោះ។

សៀវភៅ គឺជាសេរីភាពរបស់អ្នកនិពន្ធ ព្រោះពួកគេអាចបញ្ចេញគំនិតគ្រប់យ៉ាងបាន។ សៀវភៅ ក៏ជាសេរីភាពរបស់អ្នកអានផងដែរ ព្រោះអ្នកអានអាចជ្រើសរើសអានពេលណាក៏បាន ឬអានដោយរបៀបណាក៏បាន។ eBooks ជាមធ្យោបាយមួយដែលពង្រីកសេរីភាពក្នុងការអានរបស់យើង។ ប៉ុន្តែមានអ្នកខ្លះមិនទាន់ស្គាល់ eBooks ទេដែលវាក្លាយជាបញ្ហាក្នុងការលក់សៀវភៅរបស់ខ្ញុំ។

ខ្ញុំសរសេរសៀវភៅមួយក្បាល ដើម្បីបំពេញបំណងរបស់ខ្ញុំក្នុងការលក់ eBooks ផង ហើយបើសិនជាអាច ខ្ញុំចង់អ្នកអានទាំងអស់យល់ឱ្យបានច្រើនពី eBooks ។ ក្នុងនេះ គ្រាន់តែជាពត៌មានទូទៅប៉ុណ្ណោះ ខ្ញុំមិនបានបង្ហាញពីរបៀបសរសេរ ឬរបៀបបង្កើតជា ebooks នោះទេ។

សំណួរទាំង១០ក្នុងនេះ សុទ្ធតែត្រូវបានឆ្លើយយ៉ាងមិនយកចិត្តទុកដាក់ពីខ្ញុំ។ ខ្ញុំឆ្លើយចេញពីចិត្តរបស់ខ្ញុំមក ដូច្នេះខ្ញុំមិនខ្វល់ថាវាអាក្រក់ស្តាប់ ឬមានពាក្យ

មិនល្អអីទេ។ ខ្ញុំលែងខ្វល់ពីការមិនចូលចិត្តរបស់អ្នកដទៃទៅហើយ ហេតុនេះការសរសេររបស់ខ្ញុំកាន់តែងាយជាងមុន។

អ្នកណាក៏អាចអានសៀវភៅនេះបានដែរ ព្រោះខ្ញុំសរសេរជាពិសេសសម្រាប់អ្នកអានផង និងអ្នកនិពន្ធផង។ សូមអានដោយប្រើខួរក្បាល!

# ១

# តើ eBooks ជាអ្វី?

បើសិនជាប្រែជាភាសាយើង  eBooks បានន័យថា សៀវភៅអេឡិចត្រូណិច ។ គេយកសៀវភៅធម្មតាដែលបោះពុម្ពជាក្រដាសទៅបំលែងធ្វើជា File របស់អេឡិចត្រូនិច។ យើងអាចអាន eBook បានដោយប្រើឧបករណ៍ទំនើបៗដូចជា ទូរស័ព្ទ tablet កុំព្យូទ័រ ឬជាពិសេស គឺ eReader ដែលគេបង្កើតឡើងសម្រាប់ការអានតែម្តង។

ដើមកំណើតពិតប្រាកដរបស់ eBooks មិនសូវច្បាស់លាស់ទេ ព្រោះខ្លះគ្រាន់តែជាប៉ាតង់ ហើយខ្លះទៀតគ្រាន់តែជាគំនិតដែលគេបានសរសេរទុក។ ប៉ុន្តែតាមរបាយការណ៍មួយចំនួន គេបានចាត់ទុក Michael S. Hart ជាអ្នកបង្កើត eBook ដំបូងគេ។

អ្នកដែលមិនធ្លាប់ស្គាល់ Hart មានមិនតិចទេ ប៉ុន្តែសម្រាប់អ្នកដែលធ្លាប់ដោនឡូដសៀវភៅពី Project Gutenberg អាចនឹងធ្លាប់លឺឈ្មោះគាត់ហើយ។ គាត់បង្កើត Project Gutenberg នេះឡើងក្នុងគោលបំណងលើកតម្កើង និងពង្រីកអក្សរសាស្ត្ររបស់មនុស្សជាតិ ដោយចែកចាយ

eBooks ចាស់ៗដែលផុតការការពារកម្មសិទ្ធិបញ្ញា និងeBooks ដែលទទួលបានការអនុញ្ញាតត្រឹមត្រូវពីអ្នកនិពន្ធ។ Project Gutenberg ជាបណ្ណាល័យឌីជីថលធំជាងគេនៅលើអ៊ីនធឺណេត ដែលមានសៀវភៅជាច្រើនសម្រាប់អាន។ ខ្ញុំក៏ដោនឡូដសៀវភៅពីវេបសាយនោះមកអានដែរ។

ក្នុងឆ្នាំ២០០០ ចាប់ផ្តើមមានទំនោរមួយរបស់សៀវភៅកើតឡើង។ គេចាប់ផ្តើមលក់សៀវភៅ និង eBooks នៅលើអ៊ីនធឺណេតដោយដើរក្នុងប្រព័ន្ធ eCommerce។ សម្រាប់សៀវភៅទូទៅ គឺគេដាក់ជាគម្រប និងមាតិកាឱ្យមើលលេង ហើយបើចង់ទិញអាន គ្រាន់តែចុចទិញ សៀវភៅនឹងបញ្ជូនទៅតាមប្រអប់សំបុត្រមិនខាន។ សម្រាប់ eBooks វិញ ក៏មិនខុសគ្នាប៉ុន្មានដែរ។

រហូតមកដល់ឆ្នាំ ២០១២ eBooks កើនឡើងខ្លាំងជាងមុន រហូតដល់មានគេបញ្ចេញយោបល់ថា eBooks នឹងជំនួសកន្លែងសៀវភៅធម្មតាទាំងអស់។ នៅពេលនោះ អ្នកនិពន្ធ និងរោងពុម្ពខ្លះមិនព្រមបោះពុម្ពជាសៀវភៅទេ គឺគេផលិតជា eBooks ហើយដាក់លក់យកតែម្តង។ នេះគ្រាន់តែជាការបារម្ភយកចំណាប់អារម្មណ៍ប៉ុណ្ណោះ ព្រោះ eBooks មិនមែនបង្កើតមកដើម្បីសម្លាប់ប្រជាប្រិយភាពរបស់សៀវភៅទេ តែវាជាជំនួយការរបស់សៀវភៅទៅវិញ។ អ្នកខ្លះទិញទាំងសៀវភៅ និង eBook ដំណាលគ្នាតែម្តង។ សៀវភៅនៅតែលក់ដាច់ eBook ក៏នៅតែមានទីផ្សារ។

# ២

# តើ eBooks មាន

# គុណសម្បត្តិអ្វីខ្លះ?

ពាក្យថាសៀវភៅ កម្រថាអត់ប្រយោជន៍ណាស់ លើកលែងតែសៀវភៅដែលគេសរសេរលើកជើងអ្នកធំណាម្នាក់ប៉ុណ្ណោះ ព្រោះសៀវភៅនោះ មិនមែនសរសេរដើម្បីឱ្យយើងអាន។ នៅក្នុងសៀវភៅ ប្រយោជន៍ខាងក្នុងរបស់ខ្ញុំ បានរៀបរាប់ពីផលប្រយោជន៍នៃការអានសៀវភៅក្រដាសរួចហើយ ។ សម្រាប់ eBook ក៏មិនខុសគ្នាប៉ុន្មានដែរពីប្រយោជន៍ទាំងនោះ តែមានចំណុចខ្លះដែលយើងគួរតែពិចារណាដែរ។

មិនមែនដោយសារតែឥលូវនេះខ្ញុំកំពុងតែលក់ eBook ទើបខ្ញុំប្រឹងបំប៉ោងប្រយោជន៍របស់វានោះទេ។ ខ្ញុំនឹងលក់ទាំងពីរ គ្រាន់តែពេលនេះខ្ញុំគ្មានលទ្ធភាពបោះពុម្ពប៉ុណ្ណោះ។

គុណសម្បត្តិទីមួយរបស់វា គឺមិនត្រូវការកន្លែងដើម្បីទុកដូចសៀវភៅធម្មតា។ ដោយសារតែវាជា file ហើយទំហំមិនសូវធំទៀត ដូច្នេះទូរស័ព្ទ ឬ Kindle

ទំហំត្រឹមតែ 4 GB ក៏អាចមានសៀវភៅដល់ទៅរាប់រយ ឬពាន់ក្បាលទៅហើយ។ ក្នុង Kindle របស់ខ្ញុំ មានសៀវភៅជាង ១០០ ក្បាលដែលខ្ញុំអាចដាក់តាមខ្លួនបាន។ បើប្រៀបធៀបនឹងសៀវភៅដែលខ្ញុំមាននៅផ្ទះ eBook មិនស៊ីកន្លែងដាក់នោះទេ។ ខ្ញុំត្រូវចំណាយទូខោអាវមួយ ដើម្បីទុកសៀវភៅដែលខ្ញុំទិញមក។

ការដែលយើងអាចដាក់ eBook បានច្រើននៅក្នុងឧបករណ៍តែមួយបែបនេះ ធ្វើឱ្យយើងមានជម្រើសច្រើន នៅពេលចង់អានសៀវភៅ។ យើងមិនអាចស្ពាយសៀវភៅជាប់ខ្លួនរាប់រយក្បាលបាន ដោយមិនទើសអ្នកដទៃនោះទេ ប៉ុន្តែយើងអាចដាក់ eBook បានរាប់រយក្បាលដោយគ្មានអ្នកណាដឹង សូម្បីតែខ្លួនយើង ក៏មិនចាប់អារម្មណ៍ផង។

គុណសម្បត្តិទីពីរ គឺតម្លៃ។ eBook មានតម្លៃគួរសមជាងសៀវភៅដែលគេបោះពុម្ព។ យើងអាចស្វែងរក eBook តម្លៃក្រោម ២ដុល្លារជាច្រើននៅលើ Amazon និងនៅលើអ៊ីនធឺណេត។ មានអ្នកនិពន្ធផ្សេងទៀតដែលមានការគិតដូចខ្ញុំ។ ពួកគេ ចូលចិត្តទិញសៀវភៅដែលមានតម្លៃថោក ហេតុនេះនៅពេលពួកគេលក់សៀវភៅដោយខ្លួនឯង តម្លៃគឺនៅលើចិត្តរបស់ពួកគេ។

ខ្ញុំរៀបចំតម្លៃសៀវភៅរបស់ខ្ញុំឱ្យបានថោកបំផុត។ សៀវភៅដែលស្តើង ខ្ញុំលក់ ១ដុល្លារ សៀវភៅក្រាស់ ខ្ញុំលក់ ២ ឬ ៣ដុល្លារដើម្បីឱ្យសមទៅតាមអ្វីដែលខ្ញុំបានដាក់បញ្ចូល។ ខ្ញុំដាក់តម្លៃបែបនេះ ដើម្បីបត់បែនតាមអ្នកដែលចង់អាន ប៉ុន្តែគ្មានលុយដើម្បីទិញ។ បើសិនជាគេមានលុយត្រឹម ៤ ឬ ៥ដុល្លារ គេអាច

ទិញបានសៀវភៅមួយក្បាល ឬពីរប៉ុណ្ណោះ តែបើគេទិញ eBooks របស់ខ្ញុំវិញ គេអាចបានពី ៤ ទៅ៥ក្បាល។

មិនមែនសៀវភៅរបស់ខ្ញុំថោក ហើយខ្លឹមសារអន់នោះទេ។ អ្នកដែលបានអានសៀវភៅខ្ញុំ អាចធ្វើការប្រៀបធៀបគ្នាជាមួយសៀវភៅបរទេសបាន។ វាអាចមិនល្អឥតខ្ចោះដូចសៀវភៅល្បីរបស់ស្រុកគេ ប៉ុន្តែក៏មិនមែនដូចអាចម៍ឆ្កែដែរ។ ដូច្នេះ អ្នកដែលមិនសូវមានលុយច្រើន ឬមិនទាន់ចេះរកលុយខ្លួនឯងអាចគិតពិចារណាលើ eBooks បាន។

គុណសម្បត្តិទីបី គឺភាពរហ័សនៃការចេញលក់។ នៅពេលដែលអ្នកនិពន្ធធ្វើការសរសេរចប់ យើងអាចទទួលបានសៀវភៅភ្លាមៗដោយមិនបាច់ចាំយូរ។ សម្រាប់សៀវភៅបោះពុម្ពវិញ ត្រូវចាំរុញចូលរោងពុម្ព ដឹកទៅរកកន្លែងបិទការ ហើយកាត់គែមសៀវភៅ និងចាំខាងបណ្ណាគារដាក់បញ្ចូលស្តុកទើបបានទិញ។

សៀវភៅពីរក្បាលដែលខ្ញុំយកទៅបោះពុម្ពជាមួយនឹង ដាំដើមជីវិត ត្រូវចាំជាងពីរខែ ទើបឃើញមានលក់លើទីផ្សារ។ បើយូរបែបនេះ អ្នកដែលចង់ទិញអានមិនអស់អារម្មណ៍អានទៅហើយ។ ការអាន ក៏ប្រើអារម្មណ៍ដែរ បានភ្លាម ទើបគេចង់ទិញអាន។ ភាពយឺតយ៉ាវនេះហើយ ដែលខ្ញុំមិនចូលចិត្ត។ ហេតុអីត្រូវរង់ចាំ បើសៀវភៅរបស់ខ្ញុំធ្វើរួចរាល់អស់ហើយហ្នឹង? សាកគិតទៅមើល។

សម្រាប់អ្នកទិញវិញ គឺអាចបានសៀវភៅក្រោយពេលទិញរួចតែម្តង។ ជាទូទៅ ក្រោយពេលគេបង់លុយឱ្យខ្ញុំរួចហើយ ខ្ញុំផ្ញើរសៀវភៅទៅឱ្យគេភ្លាមតែម្តង លើកលែងតែខ្ញុំរវល់ ឬគ្មានអ៊ីនធឺណេតនៅជាប់ខ្លួន ទើបត្រូវពន្យាពេល។

គុណប្រយោជន៍ទីបួន គឺកាត់បន្ថយការប្រើទូរស័ព្ទអត់ប្រយោជន៍របស់យើង។ យើងចំណាយពេលរាប់ម៉ោងទៅហើយនៅលើទូរស័ព្ទ ហើយភាគច្រើនគឺទៅលើរឿងអត់បានការទៀត។ អ្នកខ្លះគេប្រើទូរស័ព្ទដើម្បីរកស៊ីបានលុយមកវិញ តែភាគច្រើនមិនមែនឆ្លាតបែបនេះទេ ប្រើដើម្បីឱ្យតែបានសាកថ្មប៉ុណ្ណោះ។

ខ្ញុំឃើញមានគេប្រើលេសថា “មួយថ្ងៃៗ ចំណាយពេលមើលអេក្រង់ទូរស័ព្ទរាប់ម៉ោងទៅហើយ ចង់ឱ្យអាន eBooks ទៀត ខ្វាក់ភ្នែកអស់ហើយ”។ ខ្ញុំចង់សួរវិញដែរថា “បើដឹងថាខ្វាក់ហើយ ម៉េចក៏ខំមើលយូរធ្វើអី?” បើមិនចាំបាច់ទេ កុំមើល ហើយកាត់ពេលត្រឹមតែកន្លះម៉ោងបានហើយ មកអាន eBooks វិញទៅ វាបានផលជាង។ ទោះបីខ្វាក់ភ្នែក ក៏សមនឹងតម្លៃខ្លះដែរ។ មួយថ្ងៃៗ មើលតែរូបថតរបស់គេ លេងតែហ្គេម ហើយមើលតែរឿងសិច ហើយស្រែកថាគ្មានពេលដើម្បីអាន eBooks ។ នេះជាលេសភ្លាវ របស់អ្នកដែលមិនចេះអានសៀវភៅ។

ដោយសារតែយើងមានទូរស័ព្ទកាន់ស្ទើរតែគ្រប់គ្នា ដូច្នេះការយក eBooks ទៅដាក់ក្នុងនោះដែរ ជាឱកាសមួយសម្រាប់យើងដកខ្លួនចេញពីកន្លែងមិនបានការខ្លះ ហើយរៀនអ្វីថ្មីពីក្នុងសៀវភៅ។ កុំនិយាយថា យើងមិនទម្លាប់នឹងការអានលើអេក្រង់ទូរស័ព្ទឱ្យសោះ។ ពាក្យនេះ លែងពិតដូចមុនហើយ។ មនុស្សសម័យថ្មី ទម្លាប់នឹងការមើលអេក្រង់ ច្រើនជាងមើលលើក្រដាស។

គុណប្រយោជន៍ទីប្រាំ គឺគេមិនដឹងថាយើងអានសៀវភៅអី។ ជួនកាលយើងអានសៀវភៅដែលមិនចង់ឱ្យគេដឹង ហេតុនេះយើងអាចអានជា eBooks បាន។ ឆ្ងល់ថាសៀវភៅអីមែនទេ? សៀវភៅនិយាយអំពីសិច សៀវភៅមិនសូវល្បីឈ្មោះ ឬសៀវភៅកូនក្មេងអីហ្នឹង។ សៀវភៅទាំងនេះ ជាចំណង់ចំណូលចិត្ត និងបញ្ហាផ្ទាល់ខ្លួន ដូច្នេះ eBooks អាចបិទបាំងភ្នែកអ្នកដទៃបាន។ អ្នកណាហ៊ានអើតមកអានក្នុងទូរស័ព្ទយើងនោះ?

យើងមិនចាំបាច់បង្ហាញអ្នកដទៃថា យើងអានសៀវភៅអីរហូតនោះទេ ព្រោះធ្វើបែបនេះ គេដេញប្រាជ្ញាយើងទាន់។ ទោះបីជាមនុស្សពីរនាក់ មិនអាចអានសៀវភៅមួយក្បាលហើយយល់ដូចគ្នាមែន តែយើងមិនគួរបញ្ចេញច្រើនពេកទេ។ អ្នកដទៃ នៅតែជាអ្នកដទៃ។

# ៣

# តើ eBooks គួរតែមានតម្លៃប៉ុន្មាន?

បើចង់ឆ្លើយសំណួរនេះ គឺត្រូវមើលទៅលើការឱ្យតម្លៃរបស់មនុស្សនៅក្នុងតំបន់ដែលយើងរស់នៅ។ ដូចនៅស្រុកខ្មែរយើង មិនសូវមានអ្នកឱ្យតម្លៃសៀវភៅ និងអ្នកនិពន្ធទេ ដូច្នេះបើយើងដាក់តម្លៃថ្លៃ តើមានអ្នកណាទិញ? សូម្បីតែអ្នកដែលចេះអានសៀវភៅ ក៏មិនឱ្យតម្លៃសៀវភៅផង ចុះទម្រាំអ្នកដែលមិនធ្លាប់អានវិញ មិនកាន់តែអត់ផ្លូវទៅហើយ។

យើងត្រូវដឹងថា មនុស្សឱ្យតម្លៃទៅលើអ្វីដែលខ្លួនគេគិតថាមានតម្លៃប៉ុណ្ណោះ។ យើងជាអ្នកនិពន្ធ យើងច្បាស់ជាឱ្យតម្លៃលើសៀវភៅរបស់ខ្លួនឯងហើយ តែអ្នកដទៃមិនប្រាកដថាគិតដូចយើងទេ។

ខ្ញុំដាក់តម្លៃតាមអ្វីដែលខ្ញុំសរសេរ។ បើខ្ញុំសរសេរច្រើន ខ្ញុំតម្លើងតម្លៃទៅតាមហ្នឹង។ ខ្ញុំមិនសរសេរវែងអន្លាយដូចអ្នកបកប្រែសៀវភៅខ្លះទេ ដូច្នេះខ្ញុំអាចច្បាស់ក្នុងចិត្តថា អ្វីដែលខ្ញុំសរសេរចូលទៅក្នុងសៀវភៅ មានគោលបំណង

ច្បាស់លាស់។ ខ្ញុំមិនសរសេរដើម្បីបង្គ្រប់សន្លឹក ឬដើម្បីឱ្យអានទៅដាច់ដង្ហើមដែរ។

សៀវភៅរបស់ខ្ញុំ បើក្រោម១០០ទំព័រ ខ្ញុំលក់ក្នុងតម្លៃ ១ដុល្លារ។ ១០០ទំព័រដល់២០០ទំព័រ តម្លៃ២ដុល្លារ។ គិតតាមហ្នឹងរហូត តែខ្ញុំប្រហែលជាមិនសរសេរឱ្យលើសពី ៣០០ទំព័រទេ ព្រោះវាវែងខ្លាំងពេកសម្រាប់ខ្ញុំ។ ខ្ញុំមិនទាន់មានសមត្ថភាពសរសេរច្រើនដល់ថ្នាក់នេះទេ។ បើហ៊ានតែសរសេរ ដឹងតែច្រំដែលហើយ។

នៅមានវិធីមួយទៀត គឺខ្ញុំឱ្យតម្លៃទៅតាមប្រភេទសៀវភៅ។ បើសៀវភៅដែលខ្ញុំសរសេរនោះ បន្តភាគ ឬទាក់ទងនឹងសៀវភៅផ្សេងទៀត ខ្ញុំតម្លើងតម្លៃឱ្យស្មើគ្នាទាំងអស់ ទោះបីក្រាស់ ឬស្តើងជាងគ្នាក៏ដោយ។

ក្រៅពីកម្រាស់ និងចំនួនខ្លឹមសារ យើងអាចគិតតម្លៃតាមការប្រឹងប្រែងរបស់អ្នកនិពន្ធ។ បើអ្នកនិពន្ធប្រើពេលទៅស្រាវជ្រាវដើម្បីសរសេរសៀវភៅនោះ តម្លៃក៏គួរតែថ្លៃដែរ។ ប៉ុន្តែបើអ្នកនិពន្ធសរសេរដោយមិនសូវមានការលំបាក ឬចាយវាយធនធានច្រើនទេ សៀវភៅនោះក៏គួរតែមានតម្លៃធូរថ្លៃ។ នៅពេលដែលយើងទិញ យើងក៏គួរតែគិតពីចំណុចនេះដែរ។

សៀវភៅរបស់ខ្ញុំ សរសេរពីបទពិសោធន៍របស់ខ្ញុំ ដូច្នេះទើបខ្ញុំមិនដាក់តម្លៃខ្ពស់ពេក។ ខ្ញុំគិតថា បទពិសោធន៍ដែលខ្ញុំមាននេះ អ្នកផ្សេងទៀតក៏គេមានដូចគ្នា គ្រាន់តែមិនបញ្ចេញមកដូចខ្ញុំ ឬគេមិនចូលចិត្តការសរសេរសៀវភៅប៉ុណ្ណោះ។ ខ្ញុំមិនមើលងាយបទពិសោធន៍ខ្លួនឯងទេ ព្រោះខ្ញុំឆ្លងកាត់មកក៏មិន

ស្រួលដែរ តែខ្ញុំក៏មិនពង្រីកបទពិសោធន៍ខ្លួនឯងឱ្យហួសពីការពិតដែរ។ អ្នកនិពន្ធខ្លះបោកប្រាស់អ្នកអានដោយនិយាយថា ប្រើពេលយូរក្នុងការសរសេរ ព្រោះចង់បានការសរសើរ និងលក់បានលុយច្រើន។

នៅមានមួយទៀតដែរ ដែលអាចបញ្ជាក់ថា សៀវភៅណាគួរតែលក់ថ្លៃ និងសៀវភៅណាគួរតែលក់ថោក។ ភាពខុសប្លែក និងចំណុចលេចធ្លោ គឺជាអ្វីដែលអ្នកអានចង់បាន។ ប៉ុន្តែគួរឱ្យស្តាយអ្នកអានក្នុងស្រុកខ្មែរ ត្រូវរោងពុម្ពពង្វក់ខួរក្បាលឱ្យអានតែសៀវភៅដដែលៗ ដូចជា គន្លឹះក្លាយជាសេដ្ឋីវិធីសាស្ត្រដឹកនាំ ឬការគ្រប់គ្រងនានា។ រោងពុម្ពដឹងថាអ្នកអានក្នុងស្រុកខ្មែរ ចង់ធ្វើធំ និងចង់មានលុយ ហេតុនេះគេបកប្រែសៀវភៅណាដែលទាក់ទងនឹងរឿងនេះប៉ុណ្ណោះ។ គេមិនខ្វល់ថា ការធ្វើបែបនេះ នឹងធ្វើឱ្យការអាន ទៅជារឿងមួយដ៏គួរឱ្យធុញទ្រាន់នោះទេ។ រោងពុម្ពឯណាចេះមានគំនិតច្នៃប្រឌិតនោះ បើមានមែន ក៏មិនបកសៀវភៅពីថៃរាប់ឆ្នាំដែរ។

សៀវភៅ ដូចគ្នាបែបនេះ មិនគួរលក់ក្នុងតម្លៃថ្លៃនោះទេ។ ខ្ញុំសរសេរសៀវភៅដោយមិនយកតាមសៀវភៅដែលមានលើទីផ្សារ។ សូម្បីតែសៀវភៅសាមកុករបស់ខ្ញុំ ក៏មិនសរសេរដូចគេដែរ។ ខ្ញុំមានចំណុចដែលត្រូវលើកមកនិយាយ មិនមែននិយាយតែពីការធ្វើជាអ្នកដឹកនាំ បញ្ជាអ្នកនេះ ឬអ្នកនោះទេ។

សៀវភៅដែលខុសប្លែកពីគេ ច្រើនតែមានតម្លៃថ្លៃ។ ឧទាហរណ៍៖ សៀវភៅរបស់ Austin Kleon ដែលគាត់សរសេរពីវិធីសាស្ត្រក្នុងការលួចយកគំនិតអ្នកដទៃមកប្រើក្នុងការងារច្នៃប្រឌិត ជាសៀវភៅដែលលក់ដាច់ជាងគេមួយនៅលើ Amazon។ សៀវភៅនេះមិនត្រឹមតែមានខ្លឹមសារខុសពីគេទេ សូម្បី

តែការឌីហ្សាញរបស់វាក៏ប្លែកពីគេដែរ។ អ្នកទាំងអស់គ្នាអាចទៅទិញអាន ដោយខ្លួនឯងក៏បានដែរ ដើម្បីឱ្យដឹងថាខ្ញុំមិនបានបោកពីរឿងនេះ។ សៀវភៅ នោះមានចំណងជើង Steal Like An Artist។

នៅពេលយើងសង្កេតឃើញចំណុចទាំងនេះនៅក្នុង eBooks ហើយសូមគិត ដោយខ្លួនឯងថាគួរទិញ ឬមិនទិញ។ បើមិនទិញទេ ត្រូវធ្វើខ្លួនឱ្យថ្លៃ ហើយ ដើរចេញ កុំទៅឌឺដងដាក់គេ ព្រោះជាទូទៅ អ្នកនិពន្ធ មានគំនិតឌឺយើងវិញ ច្រើនណាស់។ កុំនៅសុខៗ ទៅធ្វើខ្លួនឱ្យខ្មាសគេ។

ចិត្តរបស់អ្នកទិញ និងអ្នកលក់មិនដូចគ្នាទេ។ អ្នកទិញចង់បានសៀវភៅល្អ ហើយថោក ចំណែកអ្នកលក់វិញចង់លក់សៀវភៅល្អក្នុងតម្លៃល្មមតែអាចយក រួចខ្លួនបាន ព្រោះសៀវភៅល្អទាមទារពេលវេលា និងការគិតច្រើនណាស់។ គ្មានចំណុចដែលអាចស្របគ្នាបានទេ។

# ៤

# តើអ្នកណាខ្លះដែលគួរអាន eBooks?

eBooks មិនមែនសម្រាប់មនុស្សគ្រប់គ្នាទេ ប៉ុន្តែមានមនុស្សមួយផ្នែកធំដែលត្រូវការវា គ្រាន់តែពួកគេមិនដឹងខ្លួនប៉ុណ្ណោះ។ ការអាន eBooks ខុសប្លែកពីការអានសៀវភៅបន្តិចប៉ុណ្ណោះ។ មនុស្សខាងក្រោម ជាអ្នកដែលគួរតែអាន eBooks ៖

ទីមួយ គឺអ្នកដែលអានសៀវភៅលឿន។ មនុស្សដែលខ្ជិលអាន មិនដឹងថាអ្នកអានលឿនចំណាយលុយច្រើនប៉ុណ្ណាទៅលើសៀវភៅនោះទេ។ ដូច្នេះបើប្តូរពីការទិញសៀវភៅមកអានជា eBooks វិញ ពួកគេអាចសល់លុយបានច្រើនណាស់។ សៀវភៅខ្លះលក់ក្នុងតម្លៃថ្លៃ ប៉ុន្តែនៅពេលគេធ្វើ eBooks វិញ គេអាចដាក់ឱ្យអាន free ទៀតផង។ យើងអាចទុកលុយទិញតែសៀវភៅណាដែលយើងស្រលាញ់ខ្លាំងបានហើយ ចំណែកសៀវភៅផ្សេងទៀត អានជា eBooks ក៏បានដូចគ្នា។

ទីពីរ គឺអ្នកដែលអានសៀវភៅច្រើនក្បាលក្នុងពេលតែមួយ។ ការអានសៀវភៅផ្សេងគ្នាក្នុងពេលតែមួយ ជារឿងសប្បាយណាស់ ជាពិសេសអ្នកដែលត្រូវការគំនិតច្នៃប្រឌិតច្រើន។ បើយើងអានសៀវភៅពីរក្បាល យើងនឹងត្រូវដាក់សៀវភៅពីរក្បាលជាប់ខ្លួន ប៉ុន្តែបើយើងអាន eBooks យើងមិនចាំបាច់ធ្វើបែបនេះទេ។

ខ្ញុំឱ្យយោបល់អានសៀវភៅ fiction  និងសៀវភៅ non-fiction ក្នុងពេលជាមួយគ្នា ព្រោះវាធ្វើឱ្យយើងចេះយកមេរៀននៅក្នុងសៀវភៅ non-fiction មកគិតទៅលើតួអង្គក្នុងរឿង fiction ។ គំនិតច្នៃប្រឌិត មិនកើតពីការអង្គុយអានសៀវភៅទាក់ទងនឹងភាពច្នៃប្រឌិតនោះទេ។ វាកើតឡើងនៅពេលយើងយកអ្វីដែលយើងបានអាន ទៅភ្ជាប់នឹងអ្វីផ្សេងទៀតដែលមិនសូវពាក់ព័ន្ធគ្នា។ ភាពច្នៃប្រឌិត កើតមាននៅពេលយើងប្រើខួរក្បាលដើម្បីបង្កើតអ្វីមួយ។

ទីបី គឺអ្នកដែលចំណាយពេលច្រើននៅលើទូរស័ព្ទ។ នេះជាជំនាន់ zombie ទូរស័ព្ទ ដែលអ្នកណាក៏អោនមើលទូរស័ព្ទដែរ។ បើជ្រុលជាខាតពេលនៅលើវាទៅហើយ ហេតុអីមិនប្រើទៅជាប្រយោជន៍អ្វី។ បើយើងគ្មានអារម្មណ៍ក្នុងការអានលើសៀវភៅ ដោយគិតថា វាមិនសូវទាន់សម័យ យើងអាចអានលើទូរស័ព្ទបាន។ មនុស្សទាន់សម័យ មិនទុកឱ្យអ្នកដទៃចេះច្រើនជាងខ្លួនទេ។ គេឆ្លៀតពេលរៀនអ្វីថ្មីជានិច្ច ព្រោះគេដឹងថា អ្នកផ្សេងក៏កំពុងតែប្រឹងរៀនដូចគ្នាដែរ។

នេះជាយោបល់ខ្ញុំទេ តែបើសិនជាអ្នកទាំងអស់គ្នាមានហេតុផលណាល្អជាង នេះ សូមផ្ញើរជាយោបល់មកកាន់ផេក Samanh EBooks របស់ខ្ញុំបាន។ ខ្ញុំនឹងដាក់បញ្ចូលនៅពេលក្រោយទៀត។

eBooks ជាតិចណូឡូជីមានប្រយោជន៍មួយ ទោះបីជាវាមិនសូវមានអ្វីប្លែកដូចតិចណូឡូជីផ្សេងទៀត តែវាជួយសម្រួលដល់ការអានសៀវភៅរបស់មនុស្សសម័យថ្មីច្រើនណាស់។ ដោយសារស្រុកយើងមិនសូវជាមានការពេញនិយមនឹង Kindle ទើបយើងមិនសូវខ្វល់ខ្វាយពី eBooks តែបើស្រុកគេវិញមនុស្សមាន Kindle ច្រើនណាស់។

# ៥

# តើអ្នកណាដែលអាចបង្កើត eBooks?

ចម្លើយ គឺយើងទាំងអស់គ្នា។ ដោយសារតែភាពងាយស្រួលក្នុងការបង្កើត ដូច្នេះអ្នកដែលចេះត្រឹមតែវាយអក្សរក្នុងកុំព្យូទ័រ ក៏អាចបង្កើត eBooks បានដែរ។ ឱ្យតែយើងមានអ្វីចង់សរសេរ យើងអាចបង្កើតជា eBooks បានហើយ។

នៅពេលខ្ញុំមានយោបល់អ្វីមួយ ឬមានវិធីសាស្ត្រអ្វីមួយដែលខ្ញុំទើបនឹងធ្វើបានផល ខ្ញុំក៏រៀបចំវាធ្វើជា eBooks ភ្លាម ព្រោះងាយស្រួលក្នុងការចែកចាយទៅអ្នកដទៃ។ យើងអាចចាត់ទុកវា ជាឧបករណ៍ដើម្បីចែករំលែកចំណេះដឹងក៏បានដែរ។ ខ្ញុំមើលរឿងសាមកុកចប់ ខ្ញុំគិតថា តួអង្គឆាវឆាវមានចំណុច

ពិសេសច្រើនដែលខ្ញុំអាចរៀនតាមបាន ហេតុនេះខ្ញុំក៏មកសរសេរជាសៀវភៅ ដើម្បីឱ្យអ្នកដទៃបានដឹងដូចខ្ញុំដែរ។

ខ្ញុំគ្មានសញ្ញាប័ត្រខាងអក្សរសាស្ត្រខ្មែរ ឬការនិពន្ធអ្វីទេ ប៉ុន្តែខ្ញុំមានអ្វីដែលចង់សរសេរ ដូច្នេះខ្ញុំអាចសរសេរបាន។ យើងមិនបាច់រំពឹងថា សៀវភៅដែលយើងសរសេរចេញមកនោះ ល្អជាងអ្នកដទៃឬអត់ទេ ព្រោះនេះជាសៀវភៅរបស់យើងប៉ុណ្ណោះ។ កុំយកស្នាដៃរបស់យើងទៅប្រៀបធៀបជាមួយគេ ព្រោះនេះជាការមើលងាយខ្លួនឯង។

ខ្ញុំប្រើកម្មវិធី Microsoft Word ដើម្បីសរសេរសៀវភៅ  បន្ទាប់មក ខ្ញុំប្រើ Photoshop និង Illustrator ដើម្បីធ្វើគម្របសៀវភៅ។ ខ្ញុំមានជំនាញក្នុងផ្នែកក្រាហ្វិចឌីហ្សាញ ដូច្នេះខ្ញុំគ្មានបញ្ហាចំពោះរឿងនេះទេ។ សម្រាប់អ្នកដែលគ្មានជំនាញ អាចសរសេរសៀវភៅតាមធម្មតាបាន ហើយរៀនពីរបៀបឌីហ្សាញសៀវភៅដោយខ្លួនឯងទៅ។ បើសិនជាចង់ធ្វើការបែបនេះរហូតដូចខ្ញុំ គួរតែចំណាយលុយបន្តិច និងពេលបន្តិចទៅរៀនក្រាហ្វិចឌីហ្សាញក៏បាន ដើម្បីឱ្យស្នាដៃយើងចេញមកកាន់តែល្អជាងមុន និងមានភាពទាក់ទាញ។

ចំពោះការសរសេរវិញ យើងត្រូវការពេលវេលាច្រើនដែរ។ បើអ្នកដែលធ្លាប់អានស្នាដៃខ្ញុំពីមុន នឹងឃើញថា ការសរសេររបស់ខ្ញុំប្តូរម្តងបន្តិចៗ ព្រោះខ្ញុំយល់បានច្រើន។ ការសរសេរ ជាជំនាញមួយដែលអាចរៀនបានពីអ្នកដទៃផង និងខ្លួនឯងផង។ ពេលយើងសរសេរយូរទៅ យើងអាចបង្កើតក្បួនខ្នាតដោយខ្លួនឯងបានហើយ។

បើចង់រៀនសរសេរសៀវភៅអ្វីក៏ដោយ ត្រូវរៀនអានសៀវភៅ fiction ជាមុន ព្រោះសៀវភៅប្រភេទនេះមានការលេងពាក្យច្រើន ហើយអាចធ្វើឱ្យអ្នកអាន ចាប់អារម្មណ៍ទៀតផង។ មិនថាយើងសរសេរសៀវភៅរបៀបណាក៏ដោយ ត្រូវ ចាំពីតួនាទីរបស់យើងនៅក្នុងសៀវភៅ។ យើងជាអ្នកនិទានរឿង ឱ្យអ្នកអាន ស្តាប់តាមរយៈតួអក្សរ ហេតុនេះត្រូវសរសេរឱ្យដូចជាយើងកំពុងនិយាយ។ កុំ សរសេរតាមបែបផ្លូវការ ព្រោះនេះជាសំណេរដែលគួរឱ្យធុញបំផុត។ eBooks ជារបស់ថ្មី យើងត្រូវប្រើសំណេររបៀបថ្មីដែរ ទើបវាត្រូវគ្នានឹងមនុស្សជំនាន់ថ្មី។

យើងគ្រាន់តែអត់ធ្មត់បន្តិច ហើយរៀនពីចំណុចមូលដ្ឋានទាក់ទងនឹងការ សរសេរ eBooks យើងនឹងអាចយល់បានហើយ។ កុំទាន់ហក់ចូលប្រឡូក នឹងវា បើយើងមិនយល់អ្វីសោះពីវា។

ទោះបីជាអ្នកណាក៏អាចសរសេរ eBooks បានមែន ប៉ុន្តែអ្នកដែលអាច សរសេរបានល្អមានមិនច្រើនទេ។ មូលហេតុ គឺមិនព្រមរៀនពីកំហុស និង ចំណុចខ្វះខាតរបស់ខ្លួនឯង។ អ្នកនិពន្ធ ត្រូវរៀនអ្វីថ្មីរាល់ថ្ងៃដើម្បីកុំឱ្យរបៀប សរសេររបស់ខ្លួនដើរថយក្រោយ។ អ្នកនិពន្ធស្រុកខ្មែរខ្លះមិនខ្វល់ពីបញ្ហានេះ ដូច្នេះទើបស្នាដៃត្រូវអ្នកអានមើលរំលង។ សរសេរដូចជំនាន់ទុំទាវ ចង់ឱ្យក្មេង ជំនាន់ហ្វេសប៊ុកអានម៉េចនឹងចូល?

"ការសរសេរ ជាជំនាញមួយដែលអាចរៀនបានពី

អ្នកដទៃផង និងខ្លួនឯងផង។"

# ៦

# តើនៅពេលណាខ្លះដែលអ្នកនិពន្ធដាក់ eBooks ឱ្យគេអាន free?

អ្នកណាក៏ចូលចិត្តរបស់ free នោះ។ eBooks មិនសូវចំណាយដើម ទុនច្រើនក្នុងការបង្កើតទេ បើយើងមិនចុះទៅស្រាវជ្រាវរាប់ឆ្នាំលើប្រធានបទមួយ ហេតុនេះគេអាចដាក់វាឱ្យអាន free បាន។

បើយើងជាអ្នកនិពន្ធ យើងគួរតែដឹងថា ពេលណាត្រូវឱ្យ និងពេលណាដែលត្រូវលក់។ យើងមិនអាចឱ្យរហូតបានទេ ព្រោះយើងត្រូវចិញ្ចឹមខ្លួនឯងដែរ។ កុំ

ដោយសារតែចង់ឱ្យគេ ហើយធ្វើឱ្យខ្លួនឯងក្រលំបាក នេះជារឿងភ្លើបំផុត។ បើអ្នកនិពន្ធភ្លើបែបនេះ ខ្ញុំគិតថា អ្នកអានមិនគួរអានសៀវភៅរបស់គាត់ទេ។ ភ្លើជាជម្ងឺដែលងាយឆ្លងណាស់ បើឆ្លងហើយគ្មានថ្នាំព្យាបាលទេ។

ខាងក្រោមនេះ ជាពេលដែលយើងគួរដាក់សៀវភៅឱ្យអ្នកអាន free ៖

ទីមួយ គឺពេលដែលយើងទើបនឹងចេញស្នាដៃលើកដំបូង។ អ្នកអានមិនស្គាល់យើងទេ ហើយក៏មិនដឹងថា យើងអាចសរសេរអ្វីល្អប៉ុណ្ណាដែរ ដូច្នេះបើយើងឱ្យគេ free គេអាចនឹងចំណាយពេលដើម្បីអានសៀវភៅយើង។ ការធ្វើបែបនេះបានន័យថា យើងប្រកាសខ្លួនឱ្យគេដឹងថា យើងជាអ្នកនិពន្ធសៀវភៅម្នាក់ដែរ។ សម័យតិចណូឡូជីបែបនេះ បើយើងមិនប្រាប់គេ គេក៏មិនដឹងដែរ។

នៅពេលខ្ញុំសរសេរ eBooks ដំបូង ខ្ញុំដាក់ឱ្យគេដោនឡូដ free ពីវេបសាយរបស់ខ្ញុំ ដើម្បីឱ្យគេដឹងថាសៀវភៅរបស់ខ្ញុំយ៉ាងម៉េច។ បន្ទាប់មកខ្ញុំបានយោបល់ត្រលប់មកវិញច្រើនណាស់។ អ្នកខ្លះចូលចិត្ត អ្នកខ្លះរិះគន់ខ្ញុំ ហើយខ្លះទៀតដោនឡូដចោលមិនអានក៏មាន។ ខ្ញុំដាក់ឱ្យគេអាន free មែន តែខ្ញុំក៏ទទួលបានមកវិញមិនតិចដែរ។ អ្នកដទៃស្គាល់ខ្ញុំកាន់តែច្រើន ហើយគេនឹងចង់អានសៀវភៅរបស់ខ្ញុំបន្ថែមទៀត។ នេះជាឱកាសរបស់ខ្ញុំដើម្បីមានឈ្មោះជាអ្នកនិពន្ធ។

នៅលើ amazon kindle នៅពេលអ្នកនិពន្ធថ្មីដាក់សៀវភៅលក់ ពួកគេច្រើនតែដាក់ឱ្យអាន free ក្នុងរយៈពេលណាមួយសិន ដើម្បីឱ្យមានគេស្គាល់។ amazon ជាទីផ្សារធំបំផុតសម្រាប់ eBooks ដូច្នេះសៀវភៅថ្មីមានឱកាស

ច្រើនដែលគេអាចមើលឃើញ ជាពិសេសអ្នកនិពន្ធដែលដាក់លក់តែលើ amazon។

បើអ្នកទាំងអស់គ្នាឃើញអ្នកនិពន្ធណាដាក់សៀវភៅឱ្យអាន free សូមកុំគិតថា គេល្ងង់ មិនចង់បានលុយ ព្រោះគេអាចនឹងចង់បានអ្វីផ្សេងក្រៅពីលុយក៏ថា បាន។ ខ្ញុំចង់បានអ្នកអានច្រើន ដូច្នេះខ្ញុំមិនសូវខ្វល់ពីរឿងលុយទេ។ ទោះបី ឥលូវខ្ញុំចាប់ផ្ដើមលក់ eBooks ក៏ដោយ ក៏ខ្ញុំនៅតែចង់បានអ្នកអានច្រើនដែរ។ ឃើញសៀវភៅដែលខ្ញុំលក់ថោកៗទេ?

ទីពីរ គឺនៅពេលដែលគេទុកវាជាប្រភពឯកសារ (resource)។ ជួនកាល eBooks ដែលគេដាក់ឱ្យយើងនោះ អាចជាផ្នែកនៃអ្វីមួយក៏ថាបាន។ ខ្ញុំចុះឈ្មោះរៀនគូរតុក្កតាអនឡាញ ហើយនៅក្នុងមេរៀនប៉ុន្មានម៉ោងនោះ អ្នកបង្រៀនក៏មាន eBooks របស់គេដែរ។ eBooks ជាផ្នែកមួយនៃការពន្យល់ ទាក់ទងនឹងរបៀបគូរ។ គេមិនលក់ទេ ប៉ុន្តែទាល់តែយើងចុះឈ្មោះរៀននឹងគេ ទើបយើងអាចយកទៅមើលបាន។

Articulate ជាក្រុមហ៊ុនមួយដែលបង្កើតកម្មវិធីដើម្បីផលិតជាមេរៀន e-Learning ហើយត្រូវបានគេយកទៅប្រើរាប់លាននាក់នៅលើពិភពលោក។ ដើម្បីប្រើកម្មវិធីនេះបាន អ្នកប្រើត្រូវបង់ថ្លៃ license ប៉ុន្មានពាន់ដុល្លារជាមុនសិន។ ខ្ញុំប្រើកម្មវិធីនេះនៅក្រុមហ៊ុនដែលខ្ញុំធ្វើការ។ Articulate សម្បូរ eBooks ណាស់ដែលអ្នកណាក៏អាចយកទៅអានបានដែរ ប៉ុន្តែយើងត្រូវសួរថា

បើអ្នកដែលមិនប្រើកម្មវិធីនេះ អានហើយតើអាចធ្វើអ្វីបាន? eBooks របស់គេជាផ្នែកមួយនៃការប្រើកម្មវិធីប៉ុណ្ណោះ។

សៀវភៅដែលអ្នកទាំងអស់គ្នាកំពុងអាននេះ ស្ថិតនៅក្នុងហេតុផលទីពីរផង និងទីបីផង។ ខ្ញុំសរសេរសៀវភៅនេះ ព្រោះខ្ញុំលក់ eBooks។ បើអ្នកដែលទិញមិនយល់ច្បាស់ពី eBooks គេក៏មិនទិញសៀវភៅ របស់ខ្ញុំដែរ។ ម្យ៉ាងទៀតសៀវភៅនេះជាអាចចាត់ទុកជាគន្លឹះខ្លីៗរបស់អ្នកចាប់ផ្តើមសរសេរ eBooks ដោយខ្លួនឯង។

ទីបី គឺនៅពេលគេធ្វើទីផ្សារ។ eBooks ស្ថិតនៅក្នុងឧបករណ៍សម្រាប់ធ្វើទីផ្សារអនឡាញយូរមកហើយ។ Bookboon.com ជាវេបសាយមួយដែលដាក់សៀវភៅពុម្ពឱ្យសិស្សសាលាដោនឡូដយកទៅអាន ព្រោះសៀវភៅពុម្ពនៅប្រទេសអាមេរិចថ្លៃខ្លាំងណាស់។ សិស្សដែលជំពាក់លុយរដ្ឋ ពិបាកក្នុងការទិញឱ្យបានគ្រប់ក្បាល ហេតុនេះពេលមានរបស់ free បែបនេះ ពួកគេនឹងកាន់តែស្រួលហើយ។ ប៉ុន្តែ នៅក្នុង eBooks ទាំងនោះ មានដាក់ផ្ទាំងផ្សាយពាណិជ្ជកម្មពីក្រុមហ៊ុនផ្សេងៗដែលជួយក្នុងការបង្កើតសៀវភៅទាំងនោះ។ Bookboon រកចំណូលដោយរបៀបនេះ។

ខ្ញុំក៏ធ្វើបែបនេះដែរ ប៉ុន្តែដោយសារខ្ញុំគ្មានអ្នកណានៅពីក្រោយខ្នង ហេតុនេះខ្ញុំដាក់សៀវភៅផ្សេងទៀតដែលខ្ញុំកំពុងលក់ឥលូវនេះ។ ដូច្នេះពេលអ្នកទាំងអស់គ្នាអានសៀវភៅនេះចប់ ហើយចង់អានសៀវភៅផ្សេងទៀត មានតែ

ត្រូវទិញសៀវភៅផ្សេងទៀតរបស់ខ្ញុំ។ អ្នកទាំងអស់គ្នា អាចមើលនៅទំព័រខាងក្រោយបាន។ ខ្ញុំលក់ eBooks ដូច្នេះខ្ញុំធ្វើទីផ្សារតាម eBooks ដែរ។

ជារួម ហេតុផលទាំងបីនេះ គឺសម្រាប់អ្នកដែលទើបចាប់ផ្ដើមសរសេរដំបូង ហើយក៏សម្រាប់អ្នកអាន ដែលមិនចង់ចំណាយលុយខុសដែរ។ ពេលឃើញគេដាក់ឱ្យអាន free យើងគួរឱ្យតែសាកបន្តិចទៅ ដើម្បីដឹងថា សៀវភៅរបស់អ្នកនិពន្ធថ្មីៗ យ៉ាងម៉េចដែរ។

ទុកឱកាសឱ្យអ្នកនិពន្ធខ្មែរបញ្ចេញស្នាដៃផង ហើយដើម្បីធ្វើបាន គឺយើងបើកចិត្តទទួលយកស្នាដៃខ្មែរឯងខ្លះ។

# ៧

# តើយើងអាចលក់ eBooks ដោយរបៀបណាខ្លះ?

យើងសុទ្ធតែដឹងហើយថា Kindle store របស់ក្រុមហ៊ុន Amazon ឬ iBook store របស់ក្រុមហ៊ុនអេបផល ជាកន្លែងដែលគេដាក់លក់ eBooks បានយ៉ាងស្រួល ប៉ុន្តែនោះជារឿងនៅស្រុកគេទេ។ មនុស្សនៅស្រុកខ្មែរដែលជំនាញខាងតាមទាន់បច្ចេកវិទ្យា តែមិនសូវចេះប្រើនេះ រកតែ credit card ជាប់ខ្លួនដើម្បីទិញទំនិញអនឡាញក៏គ្មានផង។ ទោះបីជាមានក៏មិនដឹងទិញតាមរបៀបណាដែរ។ ខ្ញុំនិយាយត្រង់ទេ មិនមែនដៀមដាមទេ។

របៀបលក់ដែលល្អបំផុត គឺ ឱ្យគេផ្ញើរលុយមកយើងមុនតាមរយៈអ្វីក៏បានដែរ ឱ្យតែគេមាន។ សម្រាប់ខ្ញុំ គឺងាយណាស់។ អ្នកណាមានកុងធនាគារ ផ្ញើរតាម

ធនាគារមក បើអ្នកណាអត់ទេ សេវាកម្មផ្ទេរប្រាក់ក្នុងស្រុកខ្មែរច្រើនណាស់ រើសមួយណាក៏បានដែរ។ តែបើសិនជារញ៉េរញ៉ៃពេក ខ្ញុំក៏ខ្ជិលទៅយកដែរ។

ដើម្បីងាយស្រួល យើងដែលជាអ្នកលក់ គ្រាន់តែវាយតារាងមួយមក ដើម្បីឱ្យគេដឹងថា យើងទទួលលុយតាមណាខ្លះ ហើយផ្ញើរឱ្យគេទៅបានហើយ។ នេះជាវិធីងាយស្រួលដើម្បីចាប់ផ្ដើមក្នុងប្រទេសយើង។

ចំពោះការធ្វើវេបសាយ ឬកម្មវិធីជា e-commerce ខ្ញុំគិតថា ដូចជាមិនទាន់ត្រូវពេលទេ។ យើងអាចធ្វើទុកមុនក៏បានដែរ តែបើចង់បង្ខំឱ្យគេប្រើឥលូវនេះប្រហែលអត់ប្រយោជន៍ទេ។ យើងរស់នៅក្នុងស្រុកខ្មែរ ត្រូវចេះយល់ចិត្តខ្មែរយើងផង។ ជនជាតិខ្មែរស្អប់ការផ្លាស់ប្ដូរណាស់ តាំងពីថ្នាក់លើ ដល់ថ្នាក់ក្រោមផុតលេខ។ កុំឃើញពួកក្មេងៗស្រែកថា "ដូរ មិនដូរ" ក្នុងពេលបោះឆ្នោត ហើយគិតថាខ្មែរចង់បានការផ្លាស់ប្ដូរឱ្យសោះ។ កម្ពុជា ប្រៀបដូចជាថ្មមួយដុំ ដែលសុខចិត្តពុកផុយ ក៏មិនអាចប្រែរូបរាងទៅជាអ្វីផ្សេងដែរ។ ខ្ញុំសំដៅលើភាគច្រើនប៉ុណ្ណោះ ជាពិសេសមនុស្សដែលមិនចង់ប្ដូរខ្លួនឯង តែរុញអ្នកដទៃឱ្យប្ដូរជំនួស។

លក់តាមកាលៈទេសៈ និងលទ្ធភាពរបស់អ្នកទិញ។ ខ្ញុំមិនចង់ប្រើពាក្យនេះទេ តែពេលខ្លះ យើងត្រូវទុកអ្នកទិញជាស្ដេចដែរ។ បង្ខំគេឱ្យដើរតាមយើងមិនងាយដូចយើងបត់បែនតាមគេនោះទេ។ បើយើងគិតថាខ្លួនជាអ្នកនិពន្ធ ត្រូវរៀនបត់បែនខ្លះ ទើបមិនក្ររហាម។

# ៨

# តើខ្ញុំគួរចំណាយលុយទិញ Kindle ដើម្បីអាន eBooks ដែរទេ?

តាមពិត នេះជាសំណួរផ្ទាល់ខ្លួនទេ ប៉ុន្តែខ្ញុំអាចឱ្យយោបល់បាន។ Kindle ល្អសម្រាប់ការអាន eBooks ណាស់។ ដោយសារតែអេក្រង់របស់វា មិនចាំងភ្នែកដូចទូរស័ព្ទ ហើយមានលក្ខណៈស្រដៀងនឹងក្រដាសដែលយើងអាចអានបានយូរជាងនៅលើទូរស័ព្ទ។

កាលពីឆ្នាំមុន ខ្ញុំទិញ Kindle មួយគ្រឿង។ ខ្ញុំទិញនេះព្រោះខ្ញុំចង់ដឹងថា គុណភាពវាយ៉ាងម៉េចប៉ុណ្ណោះ។ នៅពេលយកមកប្រើ ទើបដឹងថា ថ្មក៏កាន់បានយូរ ងាយអាន ងាយដាក់តាមខ្លួន ហើយមានសៀវភៅអានថ្មី free រហូត។ Kindle ជាឧបករណ៍អេឡិចត្រូនិចតែមួយគត់ដែលខ្ញុំទិញមួយហើយចង់ទិញមួយទៀត។ ខ្ញុំឃើញគេចេញលក់ Kindle ពណ៌សហើយឥលូវនេះចាំមើលប៉ុន្មានឆ្នាំទៀត ចាំទិញថ្មី។

តម្លៃរបស់ Kindle អាចនឹងថ្លៃបន្តិច ប៉ុន្តែប្រយោជន៍របស់វាមានច្រើនជាពិសេស គឺសម្រាប់អ្នកដែលអាន eBooks ច្រើនតែម្តង។ បើយើងមិនហ៊ានចំណាយ តើម៉េចនឹងបានរបស់ល្អប្រើទៅ? យើងចំណាយនេះក៏មិនមែនជះលុយចោលដែរ ព្រោះ Kindle ជាឧបករណ៍សម្រាប់អានប៉ុណ្ណោះ។ យើងចំណាយពេលលើ Kindle មួយម៉ោង ល្អជាងចំណាយពេលចុចទូរស័ព្ទដោយមិនបានអ្វីត្រលប់មកវិញ។

អ្នកដែលចូលចិត្តទៅដើរលេងឆ្ងាយ ហើយចង់អានសៀវភៅ ក៏កាន់តែងាយស្រួលជាមួយវា។ សៀវភៅរបស់ខ្ញុំជា file pdf មែន ប៉ុន្តែអត់មានបញ្ហានៅលើ Kindle ទេ។ កាត់លុយចំណាយអត់ប្រយោជន៍របស់យើងខ្លះទៅ យើងអាចមាន Kindle អានហើយ។

ខាងក្រោមនេះ បង្ហាញពីចំណុចមួយចំនួនដែលខ្ញុំដឹងដោយខ្លួនឯង៖

- បើសិនជាទិញ អ្នកទាំងអស់គ្នាអាចទិញក្នុងស្រុកក៏បាន ឬផ្ញើរគេទិញពីក្រៅមកក៏បានដែរ ព្រោះតម្លៃ មិនលើសគ្នាប៉ុន្មានទេ។ បើ

យើងអាចចាំបាន អាចផ្ញើរគេទិញទៅ ដើម្បីសន្សំលុយ១០ ឬ២០ដុល្លារទុក។ បើយើងមានលុយច្រើនហើយ អាចទៅទិញតាមហាងក៏បានដែរ។ នៅភ្នំពេញ មានហាងខ្លះដែលនាំចូលមកលក់ជាលក្ខណៈឯកជន ដូច្នេះយើងអាចរកមើលតាមហ្វេសប៊ុកបាន។

- បើជ្រុលជាទិញហើយ កុំទិញប្រភេទអត់ភ្លើងដូចរបស់ខ្ញុំ ព្រោះយើងនឹងត្រូវទិញមួយគ្រឿងទៀតមិនខាន ពេលប្រើយូរទៅ។ ខ្ញុំមិនជឿថាយើងមិនចង់អានសៀវភៅនៅពេលយប់នោះទេ។

- បើសិនជាអាច សូមទិញ case ដាក់ការពារផង ព្រោះ kindle ឆាប់ឆ្កូតណាស់។ អេក្រង់ របស់ខ្ញុំ ឆ្កូតច្រើនកន្លែងណាស់ព្រោះខ្ញុំដាក់វាចូលក្នុងកាតាបដែលមានរបស់រឹងច្រើន។ ដោយសារតែឆ្កូតអស់ហើយ ទើបខ្ញុំមិនរវល់។

- នៅពេលទិញមក សូមចំណាយពេលកន្លះម៉ោង ឬមួយម៉ោងដើម្បីមើលវីដេអូនៅលើ Youtube ដែលគេបង្រៀនពីតិចនិចក្នុងការប្រើផ្សេងៗ។ ខ្ញុំធានាថាអ្នកទាំងអស់គ្នានឹងមិនមានការលំបាកអ្វីទាំងអស់នៅពេលប្រើ។ Kindle ជាដៃគូរបស់អ្នកដែលចូលចិត្តអាន eBooks។

"ជីវិតដែលគ្មាន Kindle គឺជាជីវិតដែលគ្មានបណ្ណាល័យនៅក្បែរ"- Franz S. McLaren

# ៩

# តើរដ្ឋាភិបាល មាន ជួយគាំទ្រការអាន ដែរទេ?

នៅពេលខ្ញុំទៅចូលរួមកម្មវិធីពិពរណ៌សៀវភៅ មានគេសួរសំណួរមកកាន់ខ្ញុំ។ គេដែលខ្ញុំនិយាយនោះ គឺអ្នកសម្របសម្រួល។ ខ្ញុំមិនមានបញ្ហាអ្វីជាមួយគាត់ទេ ព្រោះគាត់មិនកាត់ខ្ញុំពេលដែលខ្ញុំឡើងនិយាយផ្ដេសផ្ដាស។

សំណួរអ្វី ក៏ដោយ ដែលសួរក្នុងទីសាធារណៈ ហើយមានពាក់ព័ន្ធនឹងរដ្ឋាភិបាល សុទ្ធតែជាសំណួរដែលចង់បានចម្លើយលើកជើងទាំងអស់។ ចម្លើយដែលគេចង់ឱ្យខ្ញុំឆ្លើយ គឺ រដ្ឋាភិបាលបានជួយជ្រោមជ្រែងការអាន។ ចង្រៃមែន ព្រោះខ្ញុំមិនចូលចិត្តលើកជើងរដ្ឋាភិបាល ដូច្នេះខ្ញុំឆ្លើយថា អត់។

ខ្ញុំឆ្លើយរួចហើយ ខ្ញុំក៏បន្តនិយាយផ្តេសផ្តាសបន្តទៀត ព្រោះមិនទាន់អស់ចិត្ត។ ស្រាប់តែមានស្រ្តីចំណាស់ម្នាក់ឡើងមកនិយាយកាត់ខ្ញុំតែម្តង។ ខ្ញុំគិតថា គាត់ប្រហែលជាមិនពេញចិត្តអ្វីដែលខ្ញុំនិយាយហើយមើលទៅ ទើបគាត់ទប់តណ្ហាចំណាស់ចង់បានមុខមាត់របស់គាត់មិនបានបែបនេះ។ វេទិកាដែលគេរៀបចំនោះ គឺនិយាយពីការបោះពុម្ពផ្សាយអេឡិចត្រូនិច ប៉ុន្តែគាត់ឡើងមកអួតពីការងារគាត់ក្នុងសភាផង គ្រប់គ្រងបណ្ណាល័យជាតិផងទៅវិញ។ គាត់មិនភ្លេចទេ ពីការលើកជើងរដ្ឋាភិបាល និងជួយ promote មិត្តភក្តិគាត់ម្នាក់ទៀតដែលធ្វើការនៅក្នុងបណ្ណាល័យរបស់សម្តេចតេជោ។

ពេលខ្លះ ខ្ញុំគិតថាខ្លួនឯងឈ្លើយណាស់ តែដល់ពេលឃើញគាត់ធ្វើបែបនេះទើបខ្ញុំគិតថា ខ្ញុំមិនឈ្លើយណាស់ណាទេ។ គាត់និយាយកាត់អ្នកដទៃក្នុងកម្មវិធីដែលមិនមានឈ្មោះគាត់។ គាត់មិនខុសពីថ្នាក់លើរបស់គាត់ទេ ដែលចូលចិត្តប្រើអំណាចលើអ្នកអត់អំណាច និងយកមុខមាត់គ្រប់ពេល។ នេះជាទម្លាប់របស់អ្នកធ្វើការងាររដ្ឋ មិនមែនទាំងអស់ទេ តែស្ទើរតែទាំងអស់។ អ្នកដែលធ្វើការយកស្នាដៃពិតប្រាកដ មានមិនសូវច្រើនទេ ព្រោះត្រូវពួកមនុស្សប្រភេទនេះបណ្តេញចេញអស់ហើយ។

ឥលូវយើងមកមើលហេតុផលដែលខ្ញុំឆ្លើយថា រដ្ឋាភិបាលមិនបានជួយគាំទ្រការអាននៅស្រុកខ្មែរវិញ។ ពិពរណ៌សៀវភៅ មួយឆ្នាំមានម្តង ក៏ត្រូវបានមនុស្សដូចស្រ្តីចំណាស់នោះ អះអាងថាជាការគាំទ្ររបស់រដ្ឋាភិបាល។ បើធ្វើប៉ុណ្ណឹងហៅថាគាំទ្រ ចុះការផ្សាយពីស្រាបៀរ ពេញផ្លូវ ហៅថាស្អីវិញ? ការផ្សាយបែបនោះទេ ទើបហៅថាគាំទ្រដោយអស់ពីចិត្ត។ ចំណែកពិពរណ៌

សៀវភៅនេះ ធ្វើឱ្យតែល្អមើលប៉ុណ្ណោះ។ អ្នកណាមិនដឹងថាស្រុកខ្មែរ ពូកែបង្កើតរូបភាពក្លែងក្លាយ។

នៅពេលគេប្រកាសពីចំនួនអ្នកចូលរួម ខ្ញុំគ្មានស្អីរំភើបទេ ព្រោះខ្ញុំដឹងថាអ្នកដែលទៅ មិនមែនទៅរកសៀវភៅអាន ឬទៅស្វែងយល់ពីសៀវភៅទេ។ ភាគច្រើនទៅតាមគ្នា និងទៅថតរូបលេងប៉ុណ្ណោះ។ អ្នកអានសៀវភៅមានតិចណាស់។

រដ្ឋាភិបាល មិនដែលខ្វល់ពីអ្នកនិពន្ធទេ តាំងពីដើមមក លើកលែងតែអ្នកនិពន្ធដែលចេះសរសេរលើកជើង។ រដ្ឋាភិបាល មិនដែលទុកអ្នកនិពន្ធក្នុងភ្នែកទេ។ តើអ្នកទាំងអស់គ្នាធ្លាប់លឺគេនិយាយពីអ្នកនិពន្ធដែរទេ? ប្រាកដជាអត់ហើយ ព្រោះគេមិនខ្វល់។ បើមិនខ្វល់ តើអាចគាំទ្របានទេ? បើខ្ញុំមិនខ្វល់ពីពូព្រាប សុវត្ថិ តើខ្ញុំអាចគាំទ្រគាត់ដែរទេ? សំណួរងាយៗនៅកណ្តាលវាលតែនាំគ្នាឆ្លើយចម្លើយខុស។ ស្រុកខ្មែរយើងចូលចិត្តធ្វើអីប្លែកៗណាស់ជាពិសេស រឿងខុសទំនង។

រដ្ឋាភិបាល មិនរវល់នឹងការយកស្នាដៃបរទេសមកប្រែទេ។ រដ្ឋាភិបាលមិនចេះខ្មាសគេ ក្នុងចំណុចនេះទេ ហើយនៅគិតថាល្អទៀត។ តាមពិតទៅ ចំណុចនេះមិនអាចបន្ទោសរដ្ឋាភិបាលបានទេ ព្រោះវាជាកំហុសទាំងស្រុងរបស់រោងពុម្ព និងអ្នកគាំទ្រដែលមិនចេះគិតជាច្រើន។ ប៉ុន្តែបើរដ្ឋាភិបាលមានចិត្តជួយក្នុងរឿងនេះ ហើយចេញមុខប្រដៅរោងពុម្ពដែលចាំតែស៊ីពេរពីស្រុកថៃ (សៀវភៅភាគច្រើនបកពីថៃ) ខ្ញុំជឿថា យើងនឹងឃើញអ្នកនិពន្ធថ្មីៗច្រើនជាងមុនមិនខាន។

បើសរុបមកវិញ យើងនឹងឃើញថា រដ្ឋាភិបាលមិនអាចគាំទ្រ ឬមិនចង់គាំទ្រការអានរបស់ប្រជាជនខ្មែរឡើយ។ ហេតុអីបានជាបែបនេះ? បើប្រជាជនមានការចេះដឹង ប្រទេសក៏កាន់តែរីកចម្រើន ហើយ រដ្ឋាភិបាលក៏កាន់តែក្តាប់អំណាចធំដែរ។ ហេតុអីរដ្ឋាភិបាលបែរជាមិនចង់ឱ្យប្រជាជនខ្លួនឯងចេះដឹងទៅវិញ?

រឿងបែបនេះ មិនសូវមានគេបង្រៀនយើងទេ។ ខ្ញុំមានសំណាងដោយសារខ្ញុំបានរៀនដោយចៃដន្យ ហើយខ្ញុំក៏បានយល់ខ្លះ។ តើអ្នកទាំងអស់គ្នាធ្លាប់អានទាក់ទងនឹងភាពជាអ្នកគ្រប់គ្រងដែរទេ? ខ្ញុំមិនសំដៅលើទ្រឹស្តីភាពជាអ្នកដឹកនាំដែលគេលក់ពេញផ្សារនោះទេ។ ខ្ញុំនិយាយពីការគ្រប់គ្រងមនុស្សទាំងហ្វូងក្នុងសង្គម។

នៅក្នុងសង្គមណាក៏ដោយ តែងតែមានក្រុមមនុស្សដែលខ្ពស់ជាងគេ ឆ្លាតជាងគេ និងមានអំណាចជាងគេ ចាំគ្រប់គ្រងពីលើដែរ។ គ្រប់ហេតុការណ៍សំខាន់ទាំងអស់ គឺចេញពីមនុស្សក្រុមនេះ។ ចំណែកហេតុការណ៍មិនសំខាន់គឺចេញពីយើងទាំងអស់គ្នា ហើយនឹងត្រូវសង្គមនេះជួយបំប៉ោងហេតុការណ៍មិនសំខាន់របស់យើង។ ដូច្នេះដើម្បីគ្រប់គ្រងបាន គេចាំបាច់ត្រូវគ្រប់គ្រងខួរក្បាលរបស់មនុស្សថ្នាក់ក្រោមជាមុនសិន។ ពួកគេដឹងច្បាស់ជាងយើងទៀតថា ខួរក្បាល អាចបង្កបញ្ហាដល់ភាពជាអ្នកគ្រប់គ្រងរបស់ពួកគេបាន។

ការអាន ជាសកម្មភាពគ្រោះថ្នាក់មួយដែលអ្នកដឹកនាំធំៗ មិនចង់ឱ្យវាកើតឡើងត្រឹមត្រូវចំកន្លែងនោះទេ។ គេអាចនឹងជម្រុញប្រជាជនឱ្យអានសៀវភៅមែន ប៉ុន្តែអានអ្វីដែលគេចង់ឱ្យអានប៉ុណ្ណោះ។ ដោយសារការអាន

ពេលខ្លះអាចដាស់ខួរក្បាលដែលមានទម្លាប់នៅពីក្រោមគេឱ្យភ្ញាក់ ទើប អ្នកដឹកនាំមិនចង់ឱ្យប្រជាជនអានច្រើនពេក។  បើយើងអានសៀវភៅ លើកទឹកចិត្ត ឬសៀវភៅធ្វើម្ហូប រដ្ឋាភិបាលមិនពិបាកចិត្តទេ ព្រោះសៀវភៅ ទាំងនេះមិនប៉ះពាល់ដល់ការគ្រប់គ្រងរបស់គេ។ បើអានសៀវភៅ អាសអាភាសទៀត រដ្ឋាភិបាលកាន់តែសប្បាយចិត្ត។ ថាមិនត្រូវ បង្កើត មេដាយឱ្យអ្នកដែលអានសៀវភៅបែបនេះបានច្រើនជាងគេទៀតផង។ ប៉ុន្តែ បើយើងអានសៀវភៅទាក់ទងនឹងការងើបបះបោរ ឬគំនិតប្រឆាំងវិញ ប្រាកដជាមានបញ្ហាមិនខាន។

រដ្ឋាភិបាលរបស់ស្រុកយើង ជារដ្ឋាភិបាលឆ្លាតមួយ។ ពួកគេមានសំណាង ដោយសារតែប្រជាជនខ្មែរមិននិយមអាន ហើយអ្នកដែលអានមិននិយមគិត។ អ្នកដែលចេះគិតក៏មិននិយមអានដែរ ដូច្នេះទើបអ្វីដែលគិត ចេញបានតែមួយ ជ្រុង និងមានអ្នកស្តាប់តែក្នុងហាងកាហ្វេជិតផ្ទះ។ សំណាងធំបែបនេះ បើសិនរដ្ឋាភិបាលទៅបង្គាប់ឱ្យប្រជាជនអានសៀវភៅឱ្យច្រើន និងគិតឱ្យបាន ជ្រៅទៀត បានន័យថារដ្ឋាភិបាលខ្ជិលក្នុងការគ្រប់គ្រងហើយ។ រដ្ឋាភិបាល យើងខ្ជិលធ្វើការបន្តិចមែន ប៉ុន្តែមិនខ្ជិលក្នុងការនៅពីលើគេនោះទេ។ អ្នកណា មិនចេះស្រលាញ់អំណាច គ្រាន់តែអ្នកដែលប្រកែកថាមិនស្រលាញ់នោះ មិនទាន់ចេះស្រលាញ់ប៉ុណ្ណោះ។ ត្រូវទេ?

ការអាន អាចជាការផ្សងព្រេងមួយ ព្រោះបើអានទៅចំចំណុចដែលធ្វើឱ្យ ភ្ញាក់ខ្លួន មនុស្សនឹងអាចផ្លាស់ប្តូរជីវិតបានទាំងស្រុង។ រដ្ឋាភិបាលស្អប់ការ ផ្លាស់ប្តូរបែបនេះណាស់។ ពួកគេចង់បានអ្នកដែលចេះអានសៀវភៅល្មមៗ ឬ

អ្នកចេះអានដែលមិនប្រើខួរក្បាល ដើម្បីងាយស្រួលប្រើឱ្យធ្វើការ។ ចំណែកអ្នកដែលចេះគិតខ្លាំងពេក មិនល្អសម្រាប់ការគ្រប់គ្រងទេ ជាពិសេសប្រព័ន្ធដែលគេរៀបចំយូរមកហើយ។

អ្នកទាំងអស់គ្នាធ្លាប់លឺរដ្ឋមន្ត្រីណា និយាយពីការអានសៀវភៅដែរទេ? បើមាន ក៏គេប្រាប់យើងឱ្យអានសៀវភៅអីដែរ។ បើគេជួយតម្រង់ផ្លូវឱ្យយើងទៅហើយ ថាទៅមើល យើងអាចនឹងដឹងអ្វីបានខ្លះ? បើយើងអានតែអ្វីដែលគេចង់ឱ្យយើងអាន យើងនឹងដឹងតែអ្វីដែលគេចង់ឱ្យយើងដឹងប៉ុណ្ណោះ។

ភាពឆ្លាតរបស់រដ្ឋាភិបាល ជារឿងមួយគួរឱ្យសរសើរ ប៉ុន្តែត្រូវចាំថា ពួកគេធ្វើជាគាំទ្រប៉ុណ្ណោះ។ អ្នកដែលនិយាយថារដ្ឋាភិបាលជួយគាំទ្រការអាននៅស្រុកខ្មែរ ប្រាកដជាមានជម្ងឺក្នុងខួរក្បាល។ ស្គាល់ជម្ងឺនេះទេ? គេហៅថា ជម្ងឺត្រូវគេពង្វក់ខួរក្បាល (brainwashing) ។ ខ្ញុំសរសើររដ្ឋាភិបាលមែន តែខ្ញុំនៅមើលឃើញថា ពួកគេមិនរវល់នឹងការអាន ហើយក៏មិនរវល់នឹងអ្នកនិពន្ធដែរ។

"អ្នកដែលនិយាយថារដ្ឋាភិបាលជួយគាំទ្រការអាននៅ

ស្រុកខ្មែរ ប្រាកដជាមានជម្ងឺក្នុងខួរក្បាល"

# ១០ តើអ្នកអានគួរគាំទ្រ ពេចញ្ញ ឬគាំទ្រ អ្នកនិពន្ធ?

នេះជាសំណួរវែងជាងគេនៅក្នុងសៀវភៅនេះ ហើយក៏ជាសំណួរដែលខ្ញុំចង់បង្ហាញយូរមកហើយដែរ។ នៅក្នុងសំណួរនេះ ខ្ញុំនឹងចែកជាផ្នែកៗ ដើម្បីពន្យល់ឱ្យបានច្បាស់បន្តិច ដោយប្រើពាក្យអាក្រក់ស្តាប់របស់ខ្ញុំ។

## ១០.១ ចំណុចដូចគ្នារវាងអ្នកនិពន្ធ និង ពេចញ្ញ

អ្នកនិពន្ធ និងម្ចាស់រោងពុម្ព មិនសូវជាមានកន្លែងដែលដូចគ្នាច្រើនទេ ប៉ុន្តែ មានចំណុចមួយដែលយើងអាចចាត់ទុកថាដូចគ្នាបាន គឺ សៀវភៅ។ ពួកគេ ទាញប្រយោជន៍ពីសៀវភៅដូចគ្នា។ ប្រយោជន៍ទាំងនោះ អាចជា លុយ ចំណេះដឹង មុខមាត់ និងភាពរីករាយ។

នៅពេលកំពុងសរសេរនោះ អ្នកនិពន្ធរៀនបានអ្វីថ្មីជាច្រើន ដូចជា របៀប សរសេរ ខ្លឹមសារ និងការដាក់វិន័យចំពោះខ្លួនឯង។ទម្រាំតែចេញបានមួយ ក្បាល គេត្រូវទិន្នន័យជាច្រើន នេះជាឱកាសស្រាវជ្រាវដ៏ល្អបំផុត។ អ្នកនិពន្ធ ដែលបានសរសេរសៀវភៅចប់ អាចនឹងទទួលបានលុយពីរោងពុម្ពក្នុងចំនួន តិចបំផុត ព្រោះរោងពុម្ពមិនលូវង់ឱ្យអ្នកនិពន្ធចំណេញច្រើននោះទេ។ រោងពុម្ព ក៏ត្រូវការចំណេញដែរ។ បើសំណាងល្អ ពេលដែលសៀវភៅចេញលក់ អ្នកនិពន្ធអាចនឹងត្រូវគេទទួលស្គាល់ច្រើន ប៉ុន្តែបើអត់មានអ្នកស្គាល់ក៏មិន អីដែរ ព្រោះអ្នកនិពន្ធរីករាយនៅពេលឃើញសៀវភៅខ្លួនឯងលើទីផ្សារទៅ ហើយ។

ខ្ញុំក៏ដូចគ្នា ពេលខ្ញុំឃើញសៀវភៅខ្លួនឯងតាមបណ្ណាគារ ខ្ញុំសប្បាយចិត្ត ណាស់ ទោះបីរោងពុម្ពឱ្យលុយខ្ញុំតិច ហើយឪហ្សាញគម្របសៀវភៅដូចក្មេង ទើបនឹងចេះប្រើកុំព្យូទ័រក៏ដោយ ។ ខ្ញុំសប្បាយចិត្ត ព្រោះតែខ្ញុំមានស្នាដៃអ្វីមួយ ប៉ុណ្ណោះ។ ខ្ញុំមានជំនឿថា អ្នកដែលបានបង្កើតអ្វីមួយ គឺជាមនុស្សមានតម្លៃ។ តម្លៃ អាចថ្លឹងបានតាមរយៈស្នាដៃនេះឯង។

ចំណែករោងពុម្ពវិញ ក៏មិនអន់ដែរចំពោះរឿងប្រយោជន៍នេះ។ ពេលទិញ គឺ ក្នុងតម្លៃថោក ពេលលក់ក៏លក់ក្នុងតម្លៃសមរម្យដែរ ប៉ុន្តែលក់បានយូរណាស់

ព្រោះអ្នកនិពន្ធត្រូវលក់សិទ្ធិផ្តាច់មុខឱ្យខាងរោងពុម្ព។ បើមិនលក់ទេ គឺមិនបោះឱ្យទេ ហើយរោងពុម្ពនឹងបង្ខូរហេតុផលដើម្បីបោកចិត្តអ្នកនិពន្ធរាប់មិនអស់ដើម្បីបានសៀវភៅ។ ម្ចាស់រោងពុម្ពមួយៗ និយាយមិនចាញ់ មេបក្សជួងទេ។ នៅខាងក្រៅ ពួកគាត់អាចមើលទៅដូចជាមិនសូវចេះនិយាយ តែពេលមានប្រយោជន៍មកដល់ ពួកគាត់ក៏ក្លាយជាវាគ្មិនម្នាក់ភ្លាម។

ក្រៅពីចំណេញលុយហើយ ពួកគាត់ក៏បានចំណេះដឹងដែលមានក្នុងសៀវភៅដូចអ្នកអានទូទៅដែរ។ នៅពេលដែលសៀវភៅបានចេញលក់ គាត់បានមុខមាត់ទៅឱ្យគ្រឹះស្ថានរបស់ពួកគាត់ទៀតផង។ អ្នកអានក្នុងស្រុកយើង មិនចាប់អារម្មណ៍ថាប្រភពសៀវភៅមកពីណាទេ គេមើលថារោងពុម្ពណាជាអ្នកដាក់លក់ ហើយទិញតែម្តង។ ចំណុចពិសេស គឺចូលចិត្តតែធ្វើ fan អត់ខួរ។

ម្ចាស់រោងពុម្ពសប្បាយចិត្តណាស់ នៅពេលទទួលបានអ្នកនិពន្ធថ្មីម្នាក់មកជួយការងារគាត់។ គាត់បានសមាជិកថ្មីដែលអាចរកលុយឱ្យគាត់បាន ព្រមទាំងបោកអ្នកនិពន្ធឱ្យជឿថា គាត់ជាអ្នកមកជួយទៀតផង។

## ១០.២ ចំណុចខុសគ្នារវាងអ្នកនិពន្ធ និងរោងពុម្ព

ខ្ញុំសរសេរចំណុចនេះក្នុងនាមជាអ្នកនិពន្ធ។ ខ្ញុំមិនចាំបាច់មានគេមកដាក់មុខងារឱ្យខ្ញុំទៀតទេ ខ្ញុំហៅខ្លួនឯងថា អ្នកនិពន្ធតែម្តង។ អ្នកណាមិនពេញចិត្ត ក៏

អត់ទៅ ព្រោះខ្ញុំមិនមែនកើតមកដើម្បីបំពេញចិត្តអ្នកណាទេ។ ខ្ញុំចែកដាច់រវាងអ្នកនិពន្ធ និងរោងពុម្ព ព្រោះខ្ញុំមើលឃើញចំណុចខុសគ្នាច្រើនពេក។

ទីមួយ គឺរោងពុម្ព  ជាអ្នកដើរខ្សែលើរហូត ហើយអ្នកនិពន្ធ នៅពីក្រោមគេរហូត។ ខ្ញុំមិនពេញចិត្តចំណុចនេះជាងគេ។ រោងពុម្ព ជាមុខជំនួញដូច្នេះត្រូវការប្រាក់ចំណេញ តែការជាន់ពីលើអ្នកនិពន្ធ ដើម្បីបានលុយបែបនេះជារឿងមិនត្រូវសោះ។

រោងពុម្ពនៅស្រុកខ្មែរ ចូលចិត្តទិញស្នាដៃផ្ដាច់មុខ ដើម្បីងាយស្រួលរកស៊ីនៅពេលក្រោយបន្តទៀត។ អ្នកនិពន្ធភាគច្រើន ជាអ្នកត្រូវការលុយដើម្បីរស់ដូច្នេះមានតែត្រូវលក់ស្នាដៃរបស់ខ្លួនក្នុងតម្លៃថោក។ មិនថារោងពុម្ពចំណេញបានពីសៀវភៅនោះច្រើនប៉ុណ្ណាទេ អ្នកនិពន្ធមិនទទួលបានអ្វីបន្ថែមទៀតឡើយ ទោះបីក្នុងកុងត្រាមានសរសេរបោកថា នឹងបន្ថែមលុយឱ្យពេលលក់បានច្រើនក៏ដោយ។

ខ្ញុំមិនសូវគោរពអ្នកជំនួញនៅស្រុកខ្មែរប៉ុន្មានទេ ព្រោះខ្ញុំដឹងថា នៅពីក្រោយមុខញញឹមរបស់ពួកគេ មានលាក់គំនិតដើរខ្សែលើជានិច្ច។ ពួកគេមិនត្រូវការខ្ញុំទេ គេគ្រាន់តែត្រូវការគំនិតរបស់ខ្ញុំប៉ុណ្ណោះ។

ការដើរខ្សែលើនេះ គ្មានអ្នកណាដឹងទេ ព្រោះ អ្នកនិពន្ធជាច្រើនកំសាកមិនហ៊ាននិយាយចេញមក។ ពួកគេគិតថា ពាក្យពេជន៍នៅក្នុងកុងត្រាមិនគួរឱ្យអ្នកក្រៅដឹងទេ ព្រោះនេះជារឿងសម្ងាត់។ តាមពិត កុងត្រាមិនមែនជារឿងសម្ងាត់អ្វីទេ ជាពិសេសបើកុងត្រានោះមានភាពលម្អៀងទៅខាងអ្នកជំនួញ

បែបនេះ។ បើយើងមិននិយាយ ម៉េចនឹងមានគេដឹងថា រោងពុម្ពអាក្រក់ប៉ុណ្ណា? បើយើងមិននិយាយ ធ្វើម៉េចអ្នកនិពន្ធក្រោយទៀតបានដឹងពីបញ្ហានេះដែរឬ? បើយើងមិននិយាយ វាក៏ស្មើនឹងយើងចូលរួមជាមួយនឹងរឿងអាក្រក់ដែរ។

ទីពីរ គឺរោងពុម្ព ជាប្រភេទមនុស្សស៊ីពោរ ហើយអ្នកនិពន្ធ  ជាអ្នកបង្កើតស្នាដៃ។ តើអ្នកទាំងអស់គ្នាស្អប់មនុស្សដែលមិនធ្វើអីសោះ ហើយយកគុណសម្បត្តិដែរទេ? បើស្អប់ ល្អហើយ។ យើងចេះស្អប់អំពើអាក្រក់ បានន័យថា យើងស្រលាញ់អំពើល្អហើយ។ អ្នកខ្លះសូម្បីតែរឿងអាក្រក់ក៏មិនហ៊ានស្អប់ដែរ ព្រោះខ្លាចគេថា ខ្លួនជាមនុស្សមិនល្អ ដើរស្អប់គេឯង។ ស្អប់មនុស្សអាក្រក់ ឬរឿងអាក្រក់ មិនខុសទេ។

រោងពុម្ពជាច្រើននៅស្រុកខ្មែរ បកប្រែសៀវភៅពីស្រុកក្រៅមក ដើម្បីលក់បានលឿន និងមានលុយបើកឱ្យបុគ្គលិកខ្លួនឯង។ សៀវភៅខ្លះពិបាកបកប្រែ ដូចជាសៀវភៅជំនួញជាដើម គឺគេបកពីភាសាថៃមក ព្រោះភាសាខ្មែរ និងថៃ ងាយស្រួលបកប្រែទៅវិញទៅមកណាស់។ ត្រង់ចំណុចនេះ រោងពុម្ពស៊ីពោរគេមួយលើកហើយ គឺយកអ្វីដែលគេសម្រួលពីភាសាអង់គ្លេស មកប្រែតែម្តង។

បើតាមខ្ញុំដឹង រោងពុម្ពគ្មានសុំសិទ្ធិពីគេទៀត ព្រោះនៅមានគំនិតថោកទាបមួយថា “ប្រទេសខ្មែរជាប្រទេសកំពុងអភិវឌ្ឍ ហេតុនេះ រឿងកម្មសិទ្ធិបញ្ញាគេមិនសូវប្រកាន់ទេ”។ ស៊ីពោរក៏ពូកែ រកលេសដោះសារក៏មិនណយដែរ។ បើមិនប្រកាន់រឿងកម្មសិទ្ធិបញ្ញាទេ ហេតុអីពេលបរទេសចម្លងស្នាដៃរបស់ខ្លួន ម៉េចក៏ស្រែកទាមទារម្លេះ? យករបស់គេបាន គេយកវិញ មិនសុខចិត្ត។ កម្មសិទ្ធិ

បញ្ញា មិនទាក់ទងនឹងភាពរីកចម្រើនរបស់ប្រទេសនោះទេ តែវាទាក់ទងនឹងការគោរព និងខួរក្បាលដែលចេះគិតរបស់មនុស្ស។ អ្នកដែលមិនចេះគោរពស្នាដៃគេ និងចូលចិត្តយករបស់អ្នកដទៃមកធ្វើជារបស់ខ្លួនឯង គឺជាដំបៅដែលធ្វើឱ្យកម្មសិទ្ធិបញ្ញានៅស្រុកខ្មែរ មិនដើរដូចស្រុកគេ។

ខ្មែរស្រែកជេរយួន ថាជាចោរលួចទឹកដី ប៉ុន្តែខ្លួនឯងក៏ទៅលួចរបស់គេមកប្រើដែរ គ្រាន់តែមិនមែនជាទឹកដី។ តើយើងមានអីខុសពីយួនទៅ បើធ្វើបែបនេះ? យួនយកទឹកដីខ្មែរ ដោយគ្មានបង្កើតលេសអ្វីមកបិទបាំងទេ។ គេបង្ហាញពីមហិច្ឆតារបស់គេឱ្យយើងឃើញតែម្តង ខ្លាចតែអ្នកខ្លះធ្វើមិនឃើញប៉ុណ្ណោះ។ ប៉ុន្តែខ្មែរវិញពេលលួចស្នាដៃរបស់ស្រុកក្រៅមកម្តងៗ បង្កើតលេស និងហេតុផលរាប់មិនអស់។ សម្បូរហេតុផលអីចឹងបានជាបាត់ដីអស់ហើយនៅតែស្រែកថា “មោទនភាពជាតិខ្មែរ” កើត។ ខ្មែរស្អប់យួន តែខ្លួនឯងមានចរិតមិនខុសពីយួនដែរ។

ដោយសាររោងពុម្ពមិនសូវឱ្យតម្លៃទៅលើអ្នកនិពន្ធ ដូច្នេះមិនសូវមានអ្នកនិពន្ធណាទ្រាំធ្វើការជាមួយបានទេ។ រោងពុម្ពក៏ខ្វះអ្នកនិពន្ធទៅ ប៉ុន្តែគេមិនខ្វល់ពីចំណុចនេះទេ។ គេប្រកាសរើសបុគ្គលិកដើម្បីបកប្រែសៀវភៅបន្តទៀត។ ចរិតស៊ីពេរ ធ្វើឱ្យមនុស្សមានមោទនភាពគ្រប់ពេល ព្រោះអ្វីដែលពួកគេទទួលបានចេញពីស្នាដៃអ្នកដទៃទាំងអស់។ ខ្ញុំដឹងថាការអង្គុយបកប្រែក៏ប្រើពេលយូរដែរ ប៉ុន្តែបើប្រៀបនឹងអ្នកដែលអង្គុយសរសេរដោយខ្លួនឯង វាគ្មានអីគួរឱ្យសរសើរទេ។

តើអ្នកទាំងអស់គ្នាធ្លាប់ឆ្ងល់ដែរទេ ថាហេតុអីរោងពុម្ពមួយៗ មិនហ៊ានថាឱ្យគ្នាពីរឿងបកប្រែសៀវភៅបរទេសដោយមិនសុំសិទ្ធិ? បើមិនឆ្ងល់ទេ ចម្លែកហើយ។ ពួកគេមិននិយាយទេ ព្រោះ បើនិយាយទៅ វាដូចជាហែកកេរ្តិ៍ខ្លួនឯងឱ្យគេដឹងដែរ។ រោងពុម្ពមិនចេះលាបពណ៌គ្នាដូចពួកអ្នកនយោបាយទេ ព្រោះបើលាបទៅ គឺប្រឡាក់ទាំងសងខាង។

ទីបី គឺរោងពុម្ពឱ្យតម្លៃទៅចំនួនសៀវភៅដែលលក់បាន ចំណែកអ្នកនិពន្ធវិញឱ្យតម្លៃទៅលើគុណភាពសៀវភៅ។ អ្នកអានជាច្រើន រអ៊ូថា សៀវភៅបកប្រែអានមិនយល់។ អានម៉េចនឹងយល់ បើអ្នកបកនឹងមិនមែនជាម្ចាស់សៀវភៅផង។ បើគេសរសេរដោយខ្លួនឯង វាងាយស្រួលពន្យល់ ព្រោះគេដឹងក្នុងចិត្តថាគេចង់និយាយពីអី។ អ្នកបកប្រែគ្រាន់តែបកយកៗ ឱ្យតែចេញជាសៀវភៅប៉ុណ្ណោះ។ ខ្ញុំធ្លាប់ធ្វើការជាមួយរោងពុម្ព ដូច្នេះខ្ញុំដឹងថាពួកគេចង់បានអី។ គុណភាព មិនស្ថិតក្នុងតារាងគោលដៅរបស់គេទេ។ គេត្រូវការចំនួនច្រើនប៉ុណ្ណោះ។

រោងពុម្ពមិនខ្វល់ថា សៀវភៅដែលបកចេញមកនោះ មានគុណភាពអន់ប៉ុណ្ណាទេ សំខាន់គឺបើក្នុងមួយខែត្រូវចេញបានប៉ុន្មានក្បាល ត្រូវតែចេញបានប៉ុណ្ណឹង។ ចំណែកអ្នកនិពន្ធវិញ ប្រឹងសរសេរចង់ងាប់ ទម្រាំបានមួយក្បាល។ សៀវភៅខ្លះសរសេររាប់ខែឬរាប់ឆ្នាំ ទើបចេញជារូបរាង។ អ្វីដែលគួរឱ្យស្តាយគឺអ្នកអានក្នុងស្រុក មិនស្គាល់ពីគុណភាពរបស់សៀវភៅទេ។

ទីបួន គឺ រោងពុម្ព មានចរិតកំសាក មិនហ៊ានទទួលការពិតទេ ចំណែកអ្នកនិពន្ធវិញបង្ហាញការពិត។ ខ្ញុំមិននិយាយដល់អ្នកដែលសរសេរលាក់លៀម

ហើយហៅខ្លួនឯងថាជាអ្នកនិពន្ធទេ។ ខ្ញុំមិនយល់សោះ ហេតុអីអ្នកអាន ចូលចិត្តចរិតកំសាករបស់រោងពុម្ពកើត? អាចមកពីពួកគេជាមនុស្សកំសាក ដែរ ឬមិនមែន? គេនិយាយថា “មនុស្សកំសាក ចូលចិត្តមនុស្សកំសាកដូចគ្នា ណាស់ ព្រោះបែបនេះ ពួកគេមិនចាំបាច់មានអារម្មណ៍ថាខ្មាសអៀនទេ”។

នៅក្នុងសៀវភៅ ប្រយោជន៍ខាងក្នុង ដែលក្រោយមកត្រូវ ដាំដើមជីវិត ប្តូរ ឈ្មោះទៅជា ប្រយោជន៍នៃការអាន វិញ ខ្ញុំបានសរសេរអំពីរោងពុម្ពអផ្សុក ដែលចេញផ្សាយសៀវភៅប្រលោមលោករបស់កូរ៉េ។ ដាំដើមជីវិត បាន លុបឈ្មោះរោងពុម្ពអផ្សុក ចោល ព្រោះពួកគេមិនហ៊ានដាក់ឈ្មោះរោងពុម្ព ផ្សេងនៅក្នុងសៀវភៅរបស់ខ្លួនឯង។ ពួកគេលុបឈ្មោះទាំងអស់នៅក្នុង សៀវភៅរបស់ខ្ញុំ។ សូម្បីតែឈ្មោះ គួច ម៉េងលី ដែលខ្ញុំលើកយកមកធ្វើ ឧទាហរណ៍ក៏ត្រូវពួកគេលុបចោលដែរ ព្រោះគេខ្លាចមានរឿងជាមួយគាត់។ ខ្ញុំ ជាអ្នកសរសេរ ខ្ញុំមិនខ្លាចផង ពួកគេគ្រាន់តែស៊ីពេរបោះពុម្ពសោះ ខ្លាចអីក៏ ខ្លាចម្ល៉េះ?

ខ្ញុំដឹងថា នេះជាទម្លាប់របស់រោងពុម្ព។ ពួកគេលុបឈ្មោះសៀវភៅដើមដែលគេ បកប្រែមក ដើម្បីកុំឱ្យអ្នកអានដឹងថាជាសៀវភៅអី។ ជួនកាលអ្នកអានខ្លះ ចូលចិត្តស្រាវជ្រាវបន្ថែមអាចនឹងទៅអានសៀវភៅដើមរបស់គេ ហើយអាច នឹងដឹងថារោងពុម្ពបកប្រែខុស។ រោងពុម្ពកំសាកណាស់ ខ្លាចខ្មាសគេផង និង ខ្លាចឃើញកំហុសរបស់ខ្លួនឯង។

នៅមានចំណុចមួយទៀតដែលបញ្ជាក់ថា រោងពុម្ព និងមនុស្សដែលធ្វើការនៅ ទីនោះ ពិតជាកំសាកមែន។ ពួកគេខ្លាចការផ្លាស់ប្តូរ។ ពួកគេមិនហ៊ាន

បោះចោលការបកប្រែសៀវភៅទេ ទោះបីជាពួកគេមានសៀវភៅរាប់រយ ចំណងជើងសម្រាប់លក់ហើយក៏ដោយ។ ពួកគេមិនហ៊ានប្រថុយនឹងអ្វីថ្មីទេ។ មនុស្សកំសាកចូលចិត្តធ្វើអ្វីដដែលជានិច្ច ហេតុនេះ ទើបរោងពុម្ពនៅតែបន្ត បោះពុម្ពសៀវភៅប្រភេទដដែលៗ ទៅឱ្យអ្នកអានដដែលៗដូចគ្នា។

ចរិតកំសាករបស់រោងពុម្ព បានចែករំលែកទៅដល់ fan និងអ្នកអានរបស់គេទាំងអស់។ អ្នកអានទាំងនោះក៏កំសាកដូចគ្នាដែរ។ ពួកគេមិនហ៊ានអានសៀវភៅប្រភេទផ្សេង មិនហ៊ានលើកពីកំហុសរបស់រោងពុម្ព និងមិនហ៊ានអានសៀវភៅម្ចាស់ដើម។ សៀវភៅបកប្រែ ប្រៀបដូចជាបទចម្រៀងដែលចម្លងពីគេអ៊ីចឹង។ យល់ទេ? ទោះបីជាវាចេញមកជាភាសាខ្មែរមែន ប៉ុន្តែយើងនៅតែចម្លងពីគេដដែល។

អ្វីដែលខ្ញុំសរសេរនៅទីនេះ ជាអ្វីដែលខ្ញុំគិត និងអ្វីដែលខ្ញុំដឹងទាំងអស់។ ខ្ញុំមិនលាក់រឿងទាំងនេះទេ ព្រោះខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាដឹងដូចខ្ញុំដែរ។ ខ្ញុំជាអ្នកនិពន្ធ មិនមែនរោងពុម្ពទេ។ របៀបសរសេររបស់ខ្ញុំផ្សេងពីការបកប្រែរបស់រោងពុម្ព។ ទោះបីខ្ញុំមិនក្លាហានដូចអ្នកវាយ MMA ឬទាហាននៅសមរភូមិមែន តែខ្ញុំមិនកំសាកទៅលួចស្នាដៃគេ ហើយហៅខ្លួនឯងថា អ្នកនិពន្ធ ដូចពួករោងពុម្ពទេ។ រោងពុម្ពមិនបានហៅខ្លួនឯងថាអ្នកនិពន្ធទេ តែពួកគេមានមុខក្នុងកម្មវិធីរបស់អ្នកនិពន្ធរហូត។

ទីប្រាំ គឺរោងពុម្ពមិនឱ្យតម្លៃទៅលើអ្នកនិពន្ធក្នុងស្រុកទេ ចំណែកអ្នកនិពន្ធវិញប្រឹងលើកអ្នកនិពន្ធដូចគ្នារហូត។ ពេលខ្លះខ្ញុំក៏មិនចូលចិត្តអ្នកនិពន្ធផ្សេងទៀតដែរ ប៉ុន្តែខ្ញុំនៅតែគោរពពួកគេដដែល ព្រោះអ្វីដែលខ្ញុំធ្វើ ពួកគេ

ក៏បានធ្វើដូចគ្នាដែរ។ បើខ្ញុំមិនគោរពអ្នកនិពន្ធខ្មែរដូចគ្នា បានន័យថាខ្ញុំមិនគោរពខ្លួនឯងដែរ។ រោងពុម្ពក្នុងស្រុកវិញ ឈរខាងសៀវភៅបរទេសរហូត។

ពេលខ្ញុំទៅជួបអ៊ំ គីម ចាន់ណា ដើម្បីសុំការងារធ្វើ ខ្ញុំបានយកសៀវភៅសាមកុករបស់ខ្ញុំទៅឱ្យគាត់មើល។ កាលនោះ ខ្ញុំសរសេរបានត្រឹមតែ ៨០ទំព័រជាងប៉ុណ្ណោះ។ ខ្ញុំរៀបរាប់ពីគម្រោងដែលខ្ញុំនឹងបញ្ចប់សៀវភៅនៅថ្ងៃក្រោយ។ គាត់យកទៅមើលមួយភ្លែត ហើយក៏មិនបញ្ចេញភាពភ្ញាក់ផ្អើលអ្វីមកវិញដែរ។ គាត់បានដើរទៅទូដាក់សៀវភៅរបស់គាត់ ហើយដកសៀវភៅភាសាថៃមួយក្បាលមកឱ្យខ្ញុំអាន។ ខ្ញុំអានមិនដាច់ ព្រោះមិនចេះអក្សរថៃ។

គាត់បានប្រាប់ថា នេះជាសៀវភៅសាមកុកដែលសរសេរដោយជនជាតិថៃ។ សៀវភៅនោះក្រាស់ណាស់ ជាប្រភេទសៀវភៅសំណួរចម្លើយ។ ខ្ញុំប្រាប់តាមត្រង់ ខ្ញុំចង់ដឹងថាគេសរសេរអ្វីនៅក្នុងនោះណាស់ ព្រោះបើតាមមើលពីទម្រង់នៃការសរសេរ គឺបែបវិភាគរឿងហើយ។ គាត់បាននិយាយសរសើរសៀវភៅរបស់ថៃជាច្រើន រហូតដល់ខ្ញុំលួចគិតថា គាត់ជាជនជាតិថៃ។ គាត់ប្រាប់ថា "នៅស្រុកគេទាល់តែបណ្ឌិត ទើបអាចសរសេរសៀវភៅបាន ហើយសៀវភៅដែលគាត់បកប្រែទាំងអស់ សុទ្ធតែជាស្នាដៃរបស់បណ្ឌិត"។ គាត់មិនមើលងាយសៀវភៅរបស់ខ្ញុំទេ គ្រាន់តែគាត់គិតថា វាគ្មានអីអស្ចារ្យដូចសៀវភៅថៃប៉ុណ្ណោះ។

ខ្ញុំធ្លាប់តែ ជាអ្នកគាំទ្រសៀវភៅរបស់គាត់ ហើយសង្ឃឹមថា រោងពុម្ពគាត់នឹងគាំទ្រខ្ញុំសៀវភៅរបស់ខ្ញុំវិញដែរ ប៉ុន្តែត្រូវអស់អីនិយាយនៅពេលស្តាប់ពាក្យគាត់បែបនេះ។ ន័យរបស់គាត់ គឺ បើគ្មានសញ្ញាបណ្ឌិតទេ គ្មានលទ្ធភាព

សរសេរសៀវភៅទេ។ គាត់ជាមនុស្សចាស់ តែមិនគួរមានគំនិតចាស់គម្រិល បែបនេះសោះ។ បណ្ឌិតសរសេរសៀវភៅ មិនមែនសម្រាប់មនុស្សទូទៅអានទេ ព្រោះអ្វីដែលពួកគេចេះ ច្រើនហួសស្តង់ដារអ្នកអានធម្មតាទៅហើយ។

អស់ពីម៉ាញប៊ុក្ស ខ្ញុំក៏ទៅជួបនឹងខាងសាស្ត្រាវិញម្តង។ ខ្ញុំសូមគេធ្វើការផ្នែកនិពន្ធ តែគេប្រាប់ថា ត្រូវការអ្នកធ្វើផ្នែកលក់។ សាស្ត្រាក៏ដូចគ្នា ពេលនិយាយជាមួយខ្ញុំ ក៏ហុចសៀវភៅថៃមួយក្បាលឱ្យខ្ញុំមើលទៀត។ សៀវភៅនោះទាក់ទងនឹង Online Marketing។ គ្រាន់តែឃើញសៀវភៅថៃ ខ្ញុំអស់ទឹកចិត្តនិយាយបាត់ទៅហើយ។ ខ្ញុំប្រាប់គេថា ចាំខ្ញុំគិតមើលសិន តែតាមពិតខ្ញុំដឹងខ្លួនហើយថា មិនទៅធ្វើទេ។

ចំណុចនេះមិនទាក់ទងនឹងជាតិនិយម ឬការស្អប់ថៃទេ ប៉ុន្តែ ទាក់ទងនឹងអ្នកនិពន្ធខ្មែរ។ ហេតុអីរោងពុម្ពស្រុកខ្មែរឱ្យតម្លៃសៀវភៅរបស់ថៃខ្លាំងម្ល៉េះ? តើស្រុកខ្មែរអត់មានអ្នកចេះសរសេរសៀវភៅទេ បានជាត្រូវបកពីគេរហូតបែបនេះ?

ក្នុងឆ្នាំនេះ ខ្ញុំក៏បានធ្វើការជាមួយដាំដើមជីវិត។ ពេលដំបូង បង ប្រាជ្ញ វិជ័យ ដែលជាម្ចាស់រោងពុម្ពនិយាយជាមួយខ្ញុំធម្មតាទេ។ គាត់ថា របៀបសរសេររបស់ខ្ញុំត្រូវនឹងអ្នកអានសម័យនេះ ព្រោះគេមិនចូលចិត្តពាក្យវែងអន្លាយ ឬពាក្យវប្បធម៌ជ្រៅពេកទេ។ ខ្ញុំយល់ស្រប ព្រោះខ្ញុំគិតបែបនេះយូរហើយ។

ដោយព្រមព្រៀងគ្នារួច ខ្ញុំក៏សម្រេចថាបោះពុម្ពសៀវភៅពីរក្បាលជាមួយនឹងគាត់។ ប៉ុន្តែ នៅមុនពេលសៀវភៅចេញលក់លើទីផ្សារ គាត់បានតេរទូរស័ព្ទ

មកខ្ញុំ ហើយនិយាយថា "តាមពិត របៀបសរសេររបស់ខ្ញុំ ដូចគ្នាជាមួយអ្នកនិពន្ធថៃម្នាក់ដែលល្បីល្បាញនៅស្រុករបស់គេ”។ គាត់ថារបៀបសរសេររបស់ខ្ញុំនេះ គេឱ្យឈ្មោះថា “ប្រជានិយម"។ ខ្ញុំមិនខ្វល់ថាប្រជានិយមអាចម៍គោអីទេ។ គាត់និយាយបែបនេះ ចង់បានន័យថា ខ្ញុំចម្លងរបៀបសរសេរពីថៃហើយ។

គាត់ចូលចិត្តបកប្រែសៀវភៅពីថៃ ហើយដឹងថាខ្ញុំមិនចូលចិត្តចំណុចនេះ ទើបគាត់រកលេសឱ្យខ្ញុំដូចគាត់ដែរ។ ខ្ញុំមិនចេះអក្សរថៃផង ហើយមិនដែលទិញសៀវភៅថៃមកអានទៀត។ ចំពោះប្រទេសថៃនេះ ខ្ញុំមើលស្រីស្អាត និងខ្មើយស្អាតប៉ុណ្ណោះ ក្រៅពីនេះ អីក៏ខ្ញុំមិនចាប់អារម្មណ៍ដែរ។

របៀបសរសេររបស់ខ្ញុំ បានគំនិតពីសៀវភៅ Harry Potter កម្មវិធី Ellen និងរបៀបសរសេរនៅលើ Twitter។ បើគាត់មិនដឹង ហេតុអីមិនសួរខ្ញុំ? ហេតុអីចាំបាច់ចោទខ្ញុំថាលួចចម្លងពីថៃ។ ដំបូងខ្ញុំគិតថា គាត់មើលងាយខ្ញុំ តែក្រោយមកទើបខ្ញុំដឹងថា មិនមែនតែខ្ញុំទេ រោងពុម្ពមើលងាយអ្នកនិពន្ធគ្រប់គ្នាទាំងអស់។

រោងពុម្ពដែលយើងគិតថា ជាកន្លែងដែលលើកស្ទួយអ្នកនិពន្ធ បែរទៅជាកន្លែងដែលធ្វើឱ្យអ្នកនិពន្ធអស់តម្លៃទៅវិញ។ លុយក៏ឱ្យតិច ពាក្យសរសើរក៏អត់មាន ហើយលួចកែអត្ថន័យសៀវភៅរបស់គេទៀត។ ខ្ញុំចូលចិត្តនិយាយអាក្រក់ពីរោងពុម្ពណាស់ ព្រោះរោងពុម្ពសំបូររឿងអាក្រក់ពេក។ ខ្ញុំនិយាយប៉ុណ្ណឹងហើយ នៅតែមានគេមិនខ្វល់ផង ចុះទម្រាំតែអត់និយាយទៀត

មិនដឹងយ៉ាងណា? ស្រុកយើងនេះ ងាយនឹងភ្ញាក់ផ្អើល តែមិនចេះភ្ញាក់ខ្លួនទេ។ អ្នកណាក៏ដឹងដែរ គ្រាន់តែមិនហ៊ានទទួលស្គាល់ប៉ុណ្ណោះ។

## ១០.៣ បញ្ហាដែលអ្នកនិពន្ធប្រឈមមុខ

នៅពេលនិយាយដល់បញ្ហា យើងប្រាកដជានឹកឃើញដល់លុយមុនគេ ព្រោះមនុស្សភាគច្រើនមានបញ្ហារឿងលុយនេះ។ បើគិតទៅ មិនមែនមនុស្សភាគច្រើននោះទេ គឺមនុស្សទាំងអស់គ្នាមានបញ្ហារឿងលុយ។ អ្នកមានក៏ជួបបញ្ហារឿងលុយ អ្នកក្រក៏ជួបបញ្ហារឿងលុយ គ្រាន់តែស្ថិតក្នុងស្ថានការណ៍ខុសគ្នាប៉ុណ្ណោះ។ បើវាជាបញ្ហាសម្រាប់មនុស្សគ្រប់គ្នាទៅហើយ វាលែងជាបញ្ហាទៀតហើយ។

លុយ មិនមែនជាបញ្ហាសម្រាប់អ្នកនិពន្ធទេ។ គ្មានអ្នកណាកំណត់ថា អ្នកនិពន្ធ ត្រូវតែអត់លុយចាយទេ។ អ្នកនិពន្ធអាចរកការងារធ្វើ ឬមានមុខរបរអ្វីផ្សេងទៀត ដើម្បីចិញ្ចឹមជីវិតដូចអ្នកដទៃ ហើយឆ្លៀតពេលខ្លះមកសរសេរសៀវភៅក៏បាន។

នៅពេលខ្ញុំទៅនិយាយផ្ដេសផ្ដាសក្នុងកម្មវិធីពិពរណ៍សៀវភៅឆ្នាំនេះ ខ្ញុំបានប្រាប់អ្នកដែលអង្គុយស្ដាប់លេងក្នុងនោះថា “បើចង់ធ្វើជាអ្នកនិពន្ធ ត្រូវរកការងារធ្វើមួយឱ្យជាប់”។ នេះជាគន្លឹះដំបូងគេក្នុងការក្លាយខ្លួនជាអ្នកនិពន្ធ។ បើយើងមានការងារធ្វើ យើងមានចំណូលគ្រប់គ្រាន់ ដូច្នេះយើងមិនបាច់ខ្វល់ពីរឿងលុយ ហើយផ្ដោតអារម្មណ៍លើការសរសេរបានយ៉ាងស្រួល។ បើសិនជាអាច គួរតែរកការងារណាដែលល្អបន្តិច ល្មមចាយ ល្មមសន្សំទុកខ្លះបាន។

អ្នកនិពន្ធដែលខ្វល់តែរឿងអត់អង្ករក្នុងឆ្នាំ មិនអាចសរសេរសៀវភៅបានយូរទេ។

ខ្ញុំគិតថា អ្នកនិពន្ធមានគំនិតច្នៃប្រឌិត និងការខំប្រឹងមិនអន់ដែរ ហេតុអីបានជារកការងារធ្វើមិនបាន? ហេតុអីរកលុយមិនបាន? តើមកពីខ្លួនឯងខ្ជិល ឬភ្លើមិនស្គាល់តម្លៃលុយ? សូមកុំឱ្យលុយមកធ្វើជាឧបសគ្គក្នុងការក្លាយជាអ្នកនិពន្ធ។ យើងជ្រើសរើសចង់ធ្វើជាអ្នកនិពន្ធ ដោយខ្លួនឯង ដូច្នេះយើងត្រូវទទួលខុសត្រូវនឹងការចិញ្ចឹមជីវិតរបស់ខ្លួនឯង។

ខ្ញុំមានការងារធ្វើ ហើយរកលុយខាងក្រៅបានទៀត។ កុំច្រលំថាខ្ញុំស៊ីលុយក្រៅដូចពួកធ្វើការរដ្ឋឱ្យសោះ។ ខ្ញុំបង្រៀនគេនៅផ្ទះទេ។ ខ្ញុំយកអ្វីដែលខ្ញុំចេះពីការងារមកបង្រៀនក្នុងថ្នាក់។ ជំនាញមួយ បានលុយពីរដង ហេតុនេះទើបខ្ញុំមិនភ័យពីរឿងនេះ។  ខ្ញុំដើរចេញពីរោងពុម្ពក៏បាន មិនលក់សៀវភៅឱ្យអ្នកណាក៏បាន ព្រោះខ្ញុំអត់មានខ្វះលុយចាយទេ។ ខ្ញុំមិនមែនអ្នកមានទេ តែមានលុយចាយគ្រប់។ លុយ មិនមែនជាបញ្ហាទេ អសមត្ថភាពក្នុងការរកលុយទើបជាបញ្ហា។

យើងមកគិតពីបញ្ហាដែលអ្នកនិពន្ធប្រឈមមុខវិញ។ បញ្ហាទាំងនេះ ជាអ្វីដែលខ្ញុំកំពុងតែជួបក្នុងស្រុកយើងនេះ។ អ្នកទាំងអស់គ្នាប្រហែលជាដឹងខ្លះហើយ។

ទីមួយ គឺប្រជាជនមិននិយមអានសៀវភៅ។ សូមទោស ខ្ញុំសុំនិយាយត្រង់បន្តិចចុះ “ចរិតខ្មែរ កែមិនចេញទេ”។ ទម្លាប់របស់ប្រជាជនយើង គឺមិន

ចូលចិត្តអានតាំងពីមុនសម័យសង្គ្រាមអស់ដីទៅទៀត។ ខ្មែរចូលចិត្តនិយាយប្រគ្នា អួតពីនេះនោះ ជាពិសេសប្រធានបទអត់ប្រយោជន៍ និងការនិយាយដើមអ្នកដទៃ។ ខ្មែរគិតថា ការអានសៀវភៅមិនមែនជារឿងសប្បាយ ដូច្នេះគេជ្រើសរើសយកអ្វីផ្សេងដែលអស់លុយច្រើន ហើយសប្បាយមួយភ្លែត។ បើជំនាន់មុនវិញ ពួកបរទេសដែលមកធ្វើការនៅស្រុកខ្មែរ បានកត់សម្គាល់ថា ខ្មែរចូលចិត្តចូលមើលកុនណាស់។

យើងអាចនឹងឆ្ងល់ថា គ្រាន់តែមើលកុនខុសដែរ ចុះស្រុកគេ មើលកុនដែរនោះមិនព្រមនិយាយផង? បើយើងនិយាយបែបនេះ បានន័យថាយើងមិនដឹងខ្យល់អីពីស្រុកគេហើយ។ ចាំខ្ញុំពន្យល់ឱ្យស្ដាប់បន្តិច។ នៅស្រុកគេមុននឹងបានទៅជាខ្សែភាពយន្ត គេចេញជាសៀវភៅមុនសិន ដូច្នេះអ្នកដែលទៅមើលកុនភាគច្រើន ជាអ្នកដែលអានសៀវភៅនោះរួច។ ពួកគេចង់ដឹងថាពេលដែលយកមកថតជាភាពយន្ត តើនៅរក្សាចំណុចដើមរបស់សៀវភៅ ឬក៏កែសាច់រឿង។ អ្នកខ្លះមិនទាន់បានអានទេ ប៉ុន្តែក្រោយពេលមើលចប់ គេមិនទាន់អស់ចិត្ត ដូច្នេះគេទិញសៀវភៅអានបន្តទៀត។ អ្នកមើលកុនស្រុកគេក៏ជាអ្នកអានដែរ។ ពួកគេយល់ពីសាច់រឿងបានល្អណាស់។ តើអ្នកទាំងអស់គ្នាធ្លាប់មើលពួក fan គេវិភាគសាច់រឿងដែរទេ? ចំណុចលម្អិតនៅក្នុងសៀវភៅមានប៉ុន្មាន គេយកមកវិភាគទាំងអស់។

ចុះស្រុកខ្មែរវិញ កុនមកពីណាដែរ? បើកុនខ្មែរ រឿងត្រឹមត្រូវ មានការអប់រំល្អ គេមិនទៅមើលទេ តែបើរឿងណាថតតាមរបៀបថៃទើបគេបាក់ទ័ពទៅមើល។ វិស័យភាពយន្តស្រុកខ្មែរ គឺជាភាពអាម៉ាសមួយ ព្រោះបង្ហាញថាខ្មែរមិន

ស្គាល់អ្វីជារបស់ល្អ ហើយទោះបីជាស្គាល់របស់ល្អក៏ស្គាល់មិនច្បាស់ទៀត។ ចប់រឿងកុនប៉ុណ្ណឹងហើយ យើងបកមកការអានវិញ។

ប្រជាជន មិននិយមអានសៀវភៅទេ ព្រោះពួកគេមានការនិយមផ្សេង ដូចជានិយមសម្ភារៈទំនើប និយមផឹកស៊ី និយមអួតគ្នារឿងធ្វើខ្ញុំគេ និយមឱ្យគេបោកលុយ និយមជោរតាមគ្នា និងជាពិសេសនិយមធ្វើជាអ្នកវិភាគឯករាជ្យ។ ដឹងថាហេតុអីបានជាឯករាជ្យដែរទេ? ព្រោះវិភាគឱ្យខ្លួនឯងស្ដាប់។

គ្មានអ្នកអាន គ្មានទីផ្សារ។ អ្នកនិពន្ធ ជួបបញ្ហានេះគ្រប់គ្នា តែធ្វើអីមិនចេញ។ យើងមិនអាចបង្ខំប្រជាជនយើង ឱ្យធ្វើរឿងមានប្រយោជន៍បានទេ។

ចំពោះមូលហេតុដែលប្រជាយើងមិនអានសៀវភៅ មានច្រើនណាស់។ខ្លះជាលេស ខ្លះជាមូលហេតុពិតប្រាកដ។ ខ្ញុំធ្លាប់បានសរសេររួចមកហើយនៅក្នុងសៀវភៅប្រយោជន៍ខាងក្នុង របស់ខ្ញុំ ដូច្នេះខ្ញុំមិនសរសេរឡើងវិញទេ។ អ្នកទាំងអស់គ្នាអាចទៅរកអានបានដោយខ្លួនឯង។

ទីពីរ គឺបរទេសនិយមអត់ទំនង។ ខ្ញុំធុញទ្រាន់នឹងរោងពុម្ព និងអ្នកអានដែលស្គាល់តែអ្នកនិពន្ធបរទេសណាស់។ ខ្ញុំមិនសំដៅទៅលើអ្នកដែលអានសៀវភៅជាភាសាបរទេសនោះទេ ព្រោះការអានរបស់គេ ជាការគាំទ្រពិតប្រាកដ។ ខ្ញុំនិយាយពីសៀវភៅបកប្រែប៉ុណ្ណោះ។ រោងពុម្ព ចូលចិត្តនិយាយអីឡប់ៗ ពេលមានគេសួររឿងនេះ។ ពួកគេថា “អ្នកអានកំពុងតែត្រូវការ” ឬ “ទីផ្សារកំពុងឡើងខ្លាំង”។ តាមពិត គឺពួកគេខ្លួនឯងទេដែលបង្វិល

អ្នកអានឱ្យឃើញតែសៀវភៅបកប្រែ និងឱ្យអ្នកអានគិតថា អ្នកនិពន្ធស្រុកខ្មែរគ្មានសមត្ថភាពសរសេរទេ។

បរទេសនិយម បានន័យថា គាំទ្រស្នាដៃបរទេស ប៉ុន្តែបរទេសនិយមខុសទំនង បានន័យថា គាំទ្រការបកប្រែដែលមិនបានសុំសិទ្ធិអនុញ្ញាត ហើយគិតថាខ្លួនឯងគាំទ្រអ្នកនិពន្ធទៅវិញ។ ខ្ញុំក៏អានសៀវភៅបរទេសដែរ។ ខ្ញុំគាំទ្រអ្នកនិពន្ធខ្មែរទាំងអស់ លើកលែងតែពួកអ្នកនិពន្ធក្លែងក្លាយខ្លះដែលជ្រកខ្លួនក្រោមរោងពុម្ពណាមួយប៉ុណ្ណោះ។

បញ្ហានេះកើតពីការបកប្រែសៀវភៅ ហើយអ្នកដែលមានស្នាដៃធំជាងគេក្នុងការបង្កើតបញ្ហានេះ ប្រហែលជាម៉ាញប៊ុក្សតែម្តង។ រោងពុម្ពនេះ ចាប់ផ្តើមអាជីវកម្មបកប្រែសៀវភៅនេះមុនគេ ហើយមកដល់ឥលូវក៏នៅតែបន្តបកដែរ។ ម៉ាញប៊ុក្ស បានក្លាយជា idol នៅក្នុងភ្នែករោងពុម្ពផ្សេងទៀត ហេតុនេះទើបយើងឃើញសៀវភៅបកប្រែមានលក់កាន់តែច្រើនជាងមុន។ តើយើងមានមោទនភាពទេ ពេលប្រទេសយើង មិនឱ្យតម្លៃអ្នកនិពន្ធខ្លួនឯង ហើយលួចស្នាដៃស្រុកគេមករកលុយបែបនេះ?

ខ្ញុំជឿថា នៅតែមានមនុស្សគិតថា អ្វីដែលម៉ាញប៊ុក្ស និងរោងពុម្ព បកប្រែជាច្រើនទៀតធ្វើ ជាការជួយជាតិ ហើយខ្ញុំក៏គ្មានតួនាទីទៅកែប្រែការគិតរបស់អ្នកណាដែរ។ បើនិយាយឱ្យត្រូវតែម្តង គឺអ្នកអានដែលគាំទ្រសៀវភៅទាំងនេះអត់បានគិតពីចំណុចនេះទេ គឺមិនចេះគិតតែម្តង។ ដូច្នេះទើបពួកគេទិញសៀវភៅប្រភេទដដែលៗ (ខុសគ្នាតែចំណងជើង) ពីរោងពុម្ពមកអានរាប់ឆ្នាំហើយគ្មានបានអ្វីមកវិញសោះ។

សូមកុំប្រទាំងថា ខ្ញុំមានបញ្ហាជាមួយម៉ាញប៊ិក្សអី តាមពិតខ្ញុំមានបញ្ហាជាមួយរោងពុម្ពទាំងអស់ដែលបកប្រែសៀវភៅពីបរទេស ហើយបោះចោលអ្នកនិពន្ធក្នុងស្រុក។ ខ្ញុំមិនធ្វើដើម្បីអ្នកណាទេ ខ្ញុំធ្វើដើម្បីខ្លួនឯងប៉ុណ្ណោះ។ ខ្ញុំជាអ្នកនិពន្ធ ហេតុនេះខ្ញុំត្រូវធ្វើគ្រប់យ៉ាងដើម្បីខ្លួនឯងបែបនេះហើយ។

ទីបី គឺការលួចចម្លង។ អំពើអាក្រក់ ឆ្លងតាមគ្នាលឿនណាស់។ Christ Brown ដែលជាអ្នកចម្រៀងមាត់ស្នឹក និងក្បាលត្រងោល បានវាយមនុស្សស្រីនៅក្នុងឡាន។ អ្នកដែលគាំទ្រតារាមាត់ស្នឹកនេះបាននិយាយថា ការវាយនោះ ជាកំហុសរបស់មនុស្សស្រី។ ពួកគេនៅរកលេសជាច្រើនដើម្បីជួយលើកជើងតារាម្នាក់នេះទៀត។ តាមពិតម្នាក់នេះមានចរិតអាក្រក់តាំងពីយូរហើយ តែដោយសារតែពួកគេគាំទ្រដោយគ្មានគិត ទើបឆ្លងតាមគ្នាបែបនេះ។ ខ្ញុំជឿថា អ្នកគាំទ្រទាំងនោះនឹងវាយមនុស្សស្រីដូច Christ Brown ដែរមិនខាន ព្រោះពួកគេគិតថានេះជារឿងត្រឹមត្រូវ។

អ្នកអានសៀវភៅរបស់រោងពុម្ព ជឿថា ការលួចស្នាដៃរបស់អ្នកដទៃមករកលុយ ជារឿងជួយជាតិ និងមានប្រយោជន៍ដល់អ្នកអាន។ ពួកគេក៏ធ្វើបែបនេះដែរ។ ពួកគេធ្វើខុសគ្នាបន្តិច ដោយលួចយកស្នាដៃអ្នកនិពន្ធក្នុងស្រុកតែម្តងហើយយកទៅផ្សព្វផ្សាយដើម្បីយកមុខមាត់ខ្លួនឯង។ ពួកគេធ្វើដូចគ្នានឹងរោងពុម្ពដែរ ដោយយក Logo ខ្លួនឯងទៅដាក់លើសៀវភៅ ហើយបញ្ជាក់ថាជាកម្មសិទ្ធិរបស់ពួកគេ។

ការលួចសៀវភៅរបស់អ្នកដទៃ ទៅចែកចាយលើអ៊ីនធឺណេតដោយគ្មានគិតបែបនេះហើយ ទើបធ្វើឱ្យអ្នកនិពន្ធជួបបញ្ហា។ អ្នកនិពន្ធ គ្រប់រូបមានបំណង

នឹងយកសៀវភៅទៅលក់ ប៉ុន្តែតើអ្នកណាព្រមទិញ បើសៀវភៅមានដាក់ឱ្យដោនឡូដ free ពេញទឹកពេញដីទៅហើយហ្នឹង?

ខ្ញុំធ្លាប់ត្រូវគេលួចសៀវភៅរបស់ខ្ញុំ ហើយនៅពេលខ្ញុំទៅនិយាយជាមួយ អ្នកលួចនោះ ខ្ញុំបានទទួលមកវិញតែពាក្យភ្លើៗរបស់គេប៉ុណ្ណោះ។ អ្នកទាំងអស់គ្នាប្រាកដជាឆ្ងល់ហើយ ហេតុអីខ្ញុំចូលចិត្តប្រើពាក្យ ភ្លើ ខ្លាំងម្ល៉េះ។ មូលហេតុ គឺខ្ញុំមិនដឹងប្រើពាក្យទៅរៀបរាប់ពីមនុស្សប្រភេទនោះ។ និយាយចេញមកដូចអត់ខួរ បើមិនហៅថាភ្លើ ខ្ញុំក៏មិនដឹងថាហៅអីនោះទេ។

គេលួចសៀវភៅខ្ញុំ ហើយយក logo គេមកដាក់លើសៀវភៅខ្ញុំទៀត។ ប៉ុណ្ណឹងមិនទាន់អស់ទេ គេថា ខ្ញុំសរសេរសៀវភៅ ហេតុអីក៏ចិត្តចង្អៀតម្ល៉េះ? សរសេរមិនឱ្យគេអាន សរសេរធ្វើអី? សាកគិតទៅមើល ពាក្យអីចឹង ភ្លើ ឬមិនភ្លើ? បើយើងប្រើខួរគិតរកហេតុផលបន្តិច យើងនឹងយល់ហើយ។ ប៉ុន្តែគួរឱ្យស្ដាយគ្មានអ្នកណាគាំទ្រខ្ញុំទេ។ ពួកគេអានសៀវភៅខ្ញុំ ដល់ពេលមានគេលួចសៀវភៅខ្ញុំ ក៏នាំគ្នារត់ទៅឈរខាងអ្នកលួចអស់។ ពួកគេគិតពីប្រយោជន៍ខ្លួនឯង។ ឥលូវ ឃើញចរិតខ្ញុំហើយ ខ្ញុំមិនចាំអ្នកណាមកគាំទ្រ ឬជួយខ្ញុំទេ។ ខ្ញុំធ្វើគ្រប់យ៉ាងដោយខ្លួនឯង ព្រោះវាងាយជាងសុំអ្នកដទៃឱ្យជួយ។

ពេលនោះខ្ញុំយល់ហើយ ថាហេតុអីបានជាយួន ចេះតែចង់បានប្រទេសខ្មែរ។ យួនមើលឃើញថា ខ្មែរមានចរិតស្រដៀងយួនដែរ។ លួច គាំទ្រការលួច និងវាយប្រហារម្ចាស់ដើម។ យួនមានខ្សែភ្នែកល្អមែន។

ការលួចចម្លង ធ្វើឱ្យអ្នកនិពន្ធបាក់ទឹកចិត្ត។ ខ្ញុំមិនបាក់ទឹកចិត្តទេ ព្រោះពេលមានគេលួចរបស់ខ្ញុំ ខ្ញុំមានឱកាសទៅរករឿងគេ។ សម្រាប់ខ្ញុំ វាជារឿងសប្បាយម្យ៉ាងដែរ ព្រោះខ្ញុំដឹងថា ពួកអ្នកលួចនេះ ល្អមើលតែក្នុងហ្វេសប៊ុកប៉ុណ្ណោះ ដូច្នេះខ្ញុំធ្វើឱ្យពួកនេះបាក់មុខទៅបានហើយ។ ប៉ុន្តែអ្នកនិពន្ធផ្សេងទៀត មិនដូចខ្ញុំទេ។ គេគិតថា បើធ្វើដូចខ្ញុំជារឿងមិនល្អ ហេតុនេះពួកគេរើសយកផ្លូវឈប់សរសេរតែម្តង។

ចុះលទ្ធផលវិញ? ស្រុកខ្មែរលែងមានអ្នកកត់ត្រា។ ដល់ពេលក្រោយ ពេលចង់បានអី ក៏ត្រូវធ្វើចោកទៅសុំបរទេសមើលឯកសារ។ ប្រទេសមួយទាំងមូលអត់មានអ្នកចេះកត់ត្រា។ មានមោទនភាពទេ?

រោងពុម្ពស្រុកគេ ជាកន្លែងដែលជួយរុញអ្នកនិពន្ធទៅរកភាពជោគជ័យ និងល្បីល្បាញ ប៉ុន្តែនៅស្រុកខ្មែរវិញ ជាឧបសគ្គមួយរបស់អ្នកនិពន្ធ។ ស្នាដៃទិញផ្តាច់មុខ ហើយយកទៅកែឱ្យដូចសៀវភៅបកប្រែ។ ទិញសៀវភៅពីអ្នកនិពន្ធមិនបានមួយចំណិតគេលក់ខ្លួនមួយយប់ផង។ ប្រើពាក្យបោកប្រាស់អ្នកនិពន្ធដើម្បីស៊ីពេរពីការខំប្រឹងរបស់គេ។ អ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះ គឺស្បែកមុខក្រាស់ណាស់ ឱ្យតែបានលុយ ស៊ីពេរពីជនជាតិណាក៏មិនខ្វល់ដែរ។

ទីបួន គឺ ការផ្សព្វផ្សាយ។ អ្នកនិពន្ធ ខ្លះគិតថា ឱ្យតែសរសេរសៀវភៅហើយគឺរួចខ្លួន។ នៅពេលយើងដើរចេញពីរោងពុម្ពអស់ហ្នឹងហើយ យើងត្រូវរ៉ាប់រងគ្រប់យ៉ាងលើខ្លួនឯង។ ការផ្សព្វផ្សាយ ឥលូវនេះអាចនឹងស្រួលជាងមុន ព្រោះហ្វេសប៊ុក បានប្រើ platform របស់គេដើម្បីប្រមូលទិន្នន័យពីអ្នកប្រើប្រាស់ទាំងអស់ ហើយបន្ទាប់មកលក់ទិន្នន័យនោះទៅឱ្យអ្នកដែលចង់ទិញ។

យើងអាចទិញទិន្នន័យទាំងនោះបានក្នុងតម្លៃថោកៗ បន្ទាប់មកយើងអាចបង្ហាញសៀវភៅយើងទៅឱ្យគេឃើញបានហើយ។ បើគេចាប់អារម្មណ៍ គេនឹងទិញមិនខាន តែបើគេមិនចាប់អារម្មណ៍ ក៏គេចាប់ផ្ដើមស្គាល់យើងដែរ។

បើយើងមិនប្រាប់គេ គេក៏មិនដឹងថាយើងជាអ្នកនិពន្ធដែរ ហើយគេក៏មិនដឹងថាយើងមានសៀវភៅដើម្បីលក់។ អ្នកអានខ្លះ រង់ចាំឱ្យតែអ្នកនិពន្ធក្នុងស្រុកមានស្នាដៃដាក់លក់ប៉ុណ្ណោះ ព្រោះពួកគេក៏ធុញទ្រាន់នឹងសៀវភៅបកប្រែរបស់រោងពុម្ពដែរ។ សៀវភៅខ្លះ បកមកអានមិនយល់ ហើយប្រើពាក្យដូចក្នុងរឿងទុំទាវទៀត។ បកសៀវភៅមិនស្គាល់សម័យកាល ហើយធ្វើខ្លួនដូចបណ្ឌិត។ តាមពិត ពួកគេមានសញ្ញាប័ត្របណ្ឌិតមែន តែអត់ខួរ។ ខ្លួនឯងអត់ខួរមិនអស់ចិត្តទេ មកធ្វើឱ្យអ្នកដទៃអត់ខួរតាមដែរ។

ទីប្រាំ គឺការរិះគន់។ ចរិតថ្មីរបស់ខ្មែរយើង ទើបនឹងលេចចេញកាលពីប៉ុន្មានឆ្នាំនេះឯង។ ចរិតនេះកើតឡើង នៅពេលខ្មែរចេះប្រើបណ្ដាញសង្គម។ ពួកគេគិតថា បណ្ដាញសង្គមជាវេទិកាសាធារណៈ សម្រាប់រិះគន់អ្នកដទៃ។ គេប្រើវាដើម្បីយកមុខមាត់ខ្លួនឯង ដោយការបញ្ចេញមតិអត់ប្រយោជន៍របស់ពួកគេ។

ខ្មែរយើងចូលចិត្តធ្វើអីអត់ប្រយោជន៍ណាស់ ហើយប្រហែលជាមិនយូរទេ ភាពអត់ប្រយោជន៍ទាំងនេះនឹងឱ្យផលមកវិញហើយ។ ការរិះគន់ ជាផ្នែកមួយនៃភាពអត់ប្រយោជន៍ទាំងនោះ និងជាឧបសគ្គសម្រាប់អ្នកនិពន្ធទៀតផង។

នៅពេលអ្នកនិពន្ធព្យាយាមសរសេរសៀវភៅថ្មី នឹងមានមនុស្សចេញមុខមករិះគន់ហើយ ថាមិនល្អត្រង់នេះ មិនសូវល្អត្រង់នោះ។ តាមពិតពួកអ្នករិះគន់

នោះ មិនដែលមានសរសេរសៀវភៅអ្វីទេ។ ខ្ញុំមិនមែនជាអ្នករិះគន់ទេ។ កុំឃើញខ្ញុំនិយាយអាក្រក់ពីរោងពុម្ពបែបនេះ ហើយគិតថា ខ្ញុំមិនបានធ្វើអ្វីដូចពួកនៅលើបណ្តាញសង្គមឱ្យសោះ។ ខ្ញុំប្រឹងសរសេរឱ្យសៀវភៅរបស់ខ្ញុំ ល្អជាងសៀវភៅបកប្រែ ដើម្បីទាញយកខួរក្បាលរបស់អ្នកអានត្រលប់មកវិញ។ ខ្ញុំសរសេរដោយខ្លួនឯង និងដាក់លក់ដោយខ្លួនឯង ដើម្បីបង្ហាញអ្នកនិពន្ធក្រោយទៀតថា មិនត្រូវការរោងពុម្ព ក៏យើងអាចមានផ្លូវដើរដែរ។

រិះគន់ គឺដូចគ្នានឹងពាក្យថា “បានតែព្រុស តែមិនចេះខាំ”។ ខ្ញុំចេះខាំ។ ខ្ញុំនិយាយថា រោងពុម្ពប្រើពាក្យដូចជំនាន់ទុំទាវ ដូច្នេះពេលខ្ញុំសរសេរ ខ្ញុំប្រើពាក្យក្នុងសម័យនេះ។ ខ្ញុំថារោងពុម្ពអត់ចេះឌីហ្សាញសៀវភៅ ដូច្នេះពេលខ្ញុំឌីហ្សាញគម្របសៀវភៅ ខ្ញុំធ្វើដោយគោលការណ៍ក្នុងការឌីហ្សាញទាំងអស់។

ខ្ញុំមិនទទួលពាក្យរិះគន់ទេ ជាពិសេសចេញពីអ្នកដែលមិនធ្លាប់ធ្វើអ្វីដែលខ្ញុំកំពុងធ្វើ។ ខ្ញុំមិនមែនជាមនុស្ស ដែលអង្គុយស្តាប់ពូម៉ូតូឌុបវិភាគរឿងនយោបាយទេ។ ខ្ញុំស្តាប់អ្នកដែលមានជំនាញ មានបទពិសោធន៍ក្នុងការសរសេរសៀវភៅប៉ុណ្ណោះ។ នៅពេលមានគេមករិះគន់ ខ្ញុំនឹងគិតថា តើខ្ញុំមានពេលតបទៅវិញ ឬអត់។ បើខ្ញុំកំពុងរវល់ ខ្ញុំនឹងទុកចោលដោយមិនខ្វល់ទេ។ ប៉ុន្តែបើខ្ញុំទំនេរអត់អីធ្វើដែរ ខ្ញុំនឹងតបទៅវិញដោយពាក្យឈ្លើយបំផុតតាមដែលអាចធ្វើបាន។ ដោយសារខ្ញុំឈ្លើយស្រាប់ ដូច្នេះខ្ញុំគ្មានបញ្ហាក្នុងរឿងអស់នេះទេ។

ពេលខ្លះខ្ញុំមិនតបនឹងអ្នកដែលរិះគន់ខ្ញុំ ព្រោះខ្ញុំរវល់ប៉ុណ្ណោះ។ ពេលខ្លះខ្ញុំជាប់សរសេរសៀវភៅ ពេលខ្លះងងុយដេកពេក ហើយពេលខ្លះខ្ញុំកំពុងតែធ្វើការ។ ខ្ញុំមិនខ្លាចអ្នកមករិះគន់ខ្ញុំទេ ព្រោះខ្ញុំដឹងថាពួកនេះភាគច្រើនអត់ការងារធ្វើ ហេតុនេះបានជាទំនេរមកបញ្ចេញមតិជាមួយខ្ញុំ។ ខ្ញុំមិនមែនសម្ដេចតា ខ្ញុំមិនត្រូវការប្រជាមតិទេ។ បើចង់រិះគន់ខ្ញុំ ឈរមុខកញ្ចក់ ហើយរិះគន់ខ្លួនឯងទៅ។

ខ្ញុំអាចមិនខ្វល់នឹងការរិះគន់មែន ប៉ុន្តែអ្នកនិពន្ធផ្សេងទៀត គេមិនគិតដូចខ្ញុំទេ។ ពួកគេគិតថា ខ្លួនឯងគ្មានតម្លៃ ទើបអ្នកដទៃរិះគន់។ ពួកគេមានស្បែកមុខស្ដើងជាពោងពុម្ព ហើយក៏សម្រេចចិត្តឈប់សរសេរ។ ការរិះគន់ ជាអ្នកសម្លាប់ភាពច្នៃប្រឌិតរបស់មនុស្ស។ បើយើងមិនអាចចាត់ការនឹងការរិះគន់បាន យើងក៏មិនប្រើភាពច្នៃប្រឌិតរបស់យើងបានដែរ។ អ្នកណាក៏ជាមនុស្សច្នៃប្រឌិតដែរ ប៉ុន្តែទាស់ត្រង់ថាអាចទប់ទល់នឹងគេរិះគន់បានឬអត់ប៉ុណ្ណោះ។

អ្នកនិពន្ធប្រឈមមុខនឹងការរិះគន់ច្រើន ព្រោះអាជីពនេះក្នុងស្រុកខ្មែរ ជាអាជីពមិនសូវស្ថិតស្ថេរ ព្រោះជួនកាលអាចធ្លាក់ខ្លួនក្រ ឬកាន់តែក្រ។ មានអ្នកនិពន្ធតែប៉ុន្មាននាក់ប៉ុណ្ណោះ ដែលអាចមានឡានជិះពីទឹកដៃខ្លួនឯងបាន ហើយភាគច្រើន គឺប្រឡូកក្នុងវិស័យភាពយន្ត ឬចម្រៀងទៀតផង។ អ្នកផ្សេងពីនោះ ស៊ីសៀង។

បញ្ហាទាំងអស់ខាងលើនេះ ជាអ្វីដែលខ្ញុំជួប ដូច្នេះបើមានអ្នកនិពន្ធ ណាដែលជួបនឹងរឿងអ្វីផ្សេងទៀត សូមផ្ញើរមកឱ្យខ្ញុំផង ដើម្បីបានបន្ថែមចូលទៅក្នុងសៀវភៅនេះ។ បើមិនចង់ផ្ញើរក៏មិនអីដែរ តែជួយសរសេរជាសៀវភៅមួយផង ដើម្បីឱ្យអ្នកដែលគេចង់ដឹងបានអាន។

## ១០.៤ តើយើងគួរគាំទ្រអ្នកនិពន្ធ ឬគាំទ្ររោងពុម្ព?

ខ្ញុំអត់មានចម្លើយច្បាស់លាស់ទេ ព្រោះវាជាជម្រើសផ្ទាល់ខ្លួន។ បើអ្នកទាំងអស់គ្នាចូលចិត្តខាងណា គាំទ្រខាងហ្នឹងទៅ។

យើងគួរគាំទ្ររោងពុម្ព

- បើគិតថា ការបកប្រែពីសៀវភៅថៃ ដែលគេបកប្រែម្តងរួចហើយ ជារឿងល្អ។
- បើគិតថា ការមិនគាំទ្រស្នាដៃក្នុងស្រុក មិនមែនជាបញ្ហា។
- បើគិតថា រោងពុម្ពកេងចំណេញលើអ្នកនិពន្ធ មិនមែនជារឿងរបស់យើង។
- បើគិតថា អានសៀវភៅបកប្រែ ល្អជាងអានសៀវភៅដែលនិពន្ធក្នុងស្រុក។
- បើយើងឱ្យតម្លៃ អ្នកនិពន្ធក្លែងក្លាយជាងអ្នកនិពន្ធពិតប្រាកដ។
- បើយើងគាំទ្រការលួចចម្លងពីអ្នកដទៃ ដោយគ្មានការអនុញ្ញាត។
- បើយើងចូលចិត្តអានសៀវភៅប្រភេទដដែល ហើយយកទៅធ្វើអីមិនកើត។
- បើយើងមិនស្គាល់ពាក្យថា “original”។
- បើយើងជាកូនចៅរបស់រោងពុម្ព។

- បើយើងចង់ឃើញស្រុកខ្មែរក្លាយជាស្រុកស៊ីពេរ ពីសៀវភៅបរទេសនៅថ្ងៃក្រោយ។

ប៉ុន្តែយើងគួរតែគាំទ្រអ្នកនិពន្ធវិញ

- បើយើងគិតថា មានអ្នកនិពន្ធ ទើបមានសៀវភៅថ្មីអាន។
- បើយើងគិតថា អ្នកនិពន្ធទើបជាម្ចាស់ស្នាដៃពិតប្រាកដ ដែលត្រូវគេកេងចំណេញ។
- បើយើងស្អប់សៀវភៅបកប្រែដែលអានមិនសូវយល់។
- បើយើងមិនចូលចិត្តការរកស៊ីរបស់រោងពុម្ព។
- បើយើងចង់ឃើញរោងពុម្ពងាកមកឱ្យតម្លៃអ្នកនិពន្ធវិញ។
- បើចេះឱ្យតម្លៃទៅស្នាដៃមនុស្សក្នុងស្រុក។
- បើយើងចង់ឱ្យមានអ្នកនិពន្ធថ្មីៗកើតឡើងបន្តទៀត។
- បើយើងស្គាល់អ្វីដែលអាចប៉ះពាល់មុខមាត់ប្រទេសនេះ។
- បើយើងមិនដោរតាមអ្នកដទៃ ដែលចេះតែគាំទ្រអ្វីដែលគេមើលឃើញពីខាងក្រៅ។
- បើយើងនៅមានខួរក្បាលសម្រាប់គិត។

## ១០.៥ តើយើងអាចជួយគាំទ្រអ្នកនិពន្ធដោយរបៀបណាខ្លះ?

សៀវភៅនេះមិនសរសេរដើម្បីរោងពុម្ពទេ ហើយក៏មិនសរសេរតាមរបៀបរោងពុម្ពដែរ។ អ្នកដែលធ្លាប់អានសៀវភៅចេញពីរោងពុម្ព អាចនឹងគិតថាសៀវភៅនេះសរសេរឈ្លើយណាស់ មិនចេះគោរពរោងពុម្ព។ បើសិនជាអ្នកទាំងអស់គ្នាគិតបែបនេះមែន បានន័យថា អ្នកទាំងអស់គ្នាចេះស្វែងយល់ពីសៀវភៅហើយ។ ខ្ញុំមិនគោរពរោងពុម្ពមែន។

ក្រៅពីចំណេះដឹង សៀវភៅជាផ្នែកមួយរបស់អ្នកនិពន្ធទៀតផង។ អ្នកនិពន្ធយ៉ាងម៉េច សៀវភៅគឺបែបនោះ។ ខ្ញុំជាមនុស្សឈ្លើយ ហើយមិនគោរពរោងពុម្ពទៀត ដូច្នេះសៀវភៅរបស់ខ្ញុំក៏សរសេរបែបនោះដែរ។ រោងពុម្ពរើសសៀវភៅណាស់ មុននឹងយកមកបោះពុម្ព។ សៀវភៅណាដែលអ្នកនិពន្ធសរសេរត្រង់ពេក ឬប្រឆាំងនឹងសង្គម ឬមិនគាំទ្រអំពើអាក្រក់ រោងពុម្ពមិនយកមកបោះទេ។ រោងពុម្ពខ្លាចអ្នកអាន ចេះគិតដូចអ្នកនិពន្ធទាំងអស់នោះដែរ។

រោងពុម្ពធ្វើពុតជាមនុស្សចេះដឹង និងមនុស្សល្អ ប៉ុន្តែគួរឱ្យស្តាយ ដែលមានអ្នកអានជាច្រើន ជឿលើការធ្វើពុតនេះ។ មនុស្សចេះដឹងស្អីដែលគាំទ្រតែសៀវភៅបកប្រែ? មនុស្សល្អស្អីដែលកេងចំណេញលើស្នាដៃរបស់អ្នកដទៃ? មនុស្សចេះដឹង និងមនុស្សល្អណា ដែលមិនចង់ឱ្យអ្នកអានខ្លួនឯងចេះគិតនោះ?

ខ្ញុំមិនគាំទ្ររោងពុម្ពដែលបកប្រែសៀវភៅពីគេទេ។ ខ្ញុំគាំទ្រអ្នកនិពន្ធដែលខំសរសេរសៀវភៅខ្លួនឯង មិនមែនអ្នកនិពន្ធដែលយកពាក្យអ្នកដទៃមកកែបន្តិចបន្តួចហើយដាក់ឈ្មោះខ្លួនឯងនោះដែរ។ អ្នកនិពន្ធខ្លះថោកទាបណាស់ព្រោះប្រើវិធីរបស់រោងពុម្ពដើម្បីបានសៀវភៅនឹងគេដែរ។ បើខ្លួនឯងគ្មានសមត្ថភាពសរសេរទេ ចង់ធ្វើអ្នកនិពន្ធរកអី?

បើសិនជាអ្នកទាំងអស់គ្នាគាំទ្រអ្នកនិពន្ធដែរ ខ្ញុំមានវិធីមួយចំនួនដែលអាចជួយគាំទ្រអ្នកនិពន្ធ។ មិនមែនតែអ្នកនិពន្ធខ្មែរនោះទេ ឱ្យតែអ្នកនិពន្ធដែលមានស្នាដៃខ្លួនឯង គឺត្រូវទទួលបានការគាំទ្របែបនេះទាំងអស់។

ខាងក្រោមនេះ ខ្ញុំសរសេរក្នុងនាមជាអ្នកអានពីរបៀបដែលខ្ញុំគាំទ្រអ្នកនិពន្ធ។

- ទិញសៀវភៅ ៖ បើយើងមិនទិញ អ្នកនិពន្ធក៏មិនអាចឈរជើងបានយូរដែរ។ កុំមានគំនិតថា "អ្នកដទៃទិញហើយ ខ្ញុំចាំយករបស់គេមកកូពីក៏បានដែរ"។

- អានឱ្យចប់ ៖ នេះជាការឱ្យតម្លៃទៅលើស្នាដៃរបស់អ្នកនិពន្ធ។ អានឱ្យចប់ទើបដឹងថាគេចង់សរសេរពីអី។

- ណែនាំសៀវភៅនោះទៅអ្នកដទៃ ៖ បើយើងមានមិត្តភក្តិជាអ្នកអានដែរ យើងអាចប្រាប់គេពីសៀវភៅនោះដើម្បីឱ្យសៀវភៅ កាន់តែមានអ្នកអានច្រើន។ យើងអាចប្រើបណ្តាញសង្គមដើម្បីឱ្យមនុស្សស្គាល់សៀវភៅកាន់តែច្រើន។

- សរសេរ review នៅលើប្លុក ៖ បើអ្នកទាំងអស់គ្នាមានប្លុក ឬវេបសាយផ្ទាល់ខ្លួន ការសរសេរ review អំពីសៀវភៅជាវិធីល្អមួយ ព្រោះអាចឱ្យអ្នកដទៃដឹងពីគុណភាពរបស់សៀវភៅបាន។
- ផ្ញើរអ៊ីម៉ែលទៅកាន់អ្នកនិពន្ធ ៖ ទោះបីអ្នកនិពន្ធគ្មានពេលតបក៏ដោយ ក៏គេបើកអានដែរ។ ខ្ញុំផ្ញើរអ៊ីម៉ែលប្រាប់ថា ចំណុចណាដែលខ្ញុំចូលចិត្ត និងកន្លែងណាដែលខ្ញុំមិនសូវយល់។

ខ្ញុំមិនសរសេរក្នុងនាមជាអ្នកនិពន្ធទេ ព្រោះវាមិនល្អ។

# ទំព័រចុងក្រោយ

យើងមកដល់ទីបញ្ចប់នៃសៀវភៅនេះហើយ។ សៀវភៅនេះខ្លីទេ ព្រោះនេះមិនមានជាប្រធានបទវែងនោះទេ។ ប្រធានបទងាយយល់ណាស់ តែគ្មានអ្នកចង់យល់ប៉ុណ្ណោះ។ គោលបំណងរបស់ខ្ញុំ គឺក្រោយពេលអានចប់អ្នកទាំងអស់គ្នានឹងងាកមកគាំទ្រអ្នកនិពន្ធខ្លះ។ កុំគាំទ្រដោយគ្រាន់តែចុច Like ឬ share អ្វីដែលពួកគេផុស។ ជួយទិញពួកគេផង ព្រោះបើគ្មានអ្នកជួយទេពួកគេនឹងរត់ទៅឱ្យរោងពុម្ពស៊ីពីលើទៀតហើយ ដើម្បីចិញ្ចឹមខ្លួនឯង។

ខ្ញុំមិនសរសេរបំភ្លើសអ្វីទេ នៅក្នុងនេះ ដូច្នេះអ្វីដែលអ្នកទាំងអស់គ្នាអាន គឺជាអ្វីដែលកំពុងកើតឡើងក្នុងប្រទេសរបស់យើង។ សំណួរទី៩ និងទី១០ ជាសំណួរសំខាន់ជាងគេក្នុងនេះ។ សំណួរនេះ គ្មានអ្នកឆ្លើយយូរមកហើយរហូតដល់ពេលនេះគ្មានអ្នកចង់យកមកសួរទៀត។ បើសិនមិនចាំទេ សូមបកទៅអានវិញម្តងទៀត។

ខ្ញុំសូមខ្ចីពាក្យមួយឃ្លាដែលនៅក្នុងសៀវភៅ ចរិតឆ្កែ មកប្រើបន្តិចចុះ។ ខ្ញុំគិតថា វាសមជាមួយនឹងសៀវភៅនេះជាង។ “បំផ្លាញអ្នកនិពន្ធក្នុងស្រុក ជាទង្វើរបស់មនុស្សភ្លើប៉ុណ្ណោះ”។ បើខ្លួនយើងមិនភ្លើទេ សូមកុំធ្វើភ្លើ ព្រោះ ការធ្វើភ្លើនេះ នឹងធ្វើឱ្យយើងក្លាយជាមនុស្សភ្លើមែនទែននៅថ្ងៃណាមួយមិនខាន។

ជាចុងក្រោយ ខ្ញុំសូមអរគុណម្តងទៀត សម្រាប់អ្នកដែលអានសៀវភៅរបស់ខ្ញុំកន្លងមក និងអ្នកដែលទើបនឹងចាប់ផ្តើមអាន។ អ្នកទាំងអស់គ្នាក៏អាចចូល

ទៅអានប្លុករបស់ខ្ញុំបានដែរ ព្រោះខ្ញុំមានអត្ថបទថ្មីៗ រៀងរាល់សប្តាហ៍។ អ្នកទាំងអស់គ្នាអាចផ្ញើរជាសំណួរទាក់ទងនឹងការអាន ឬការសរសេរមកខ្ញុំបាន ហើយខ្ញុំនឹងព្យាយាមឆ្លើយឱ្យបានក្បោះក្បាយ តាម ការចេះដឹងរបស់ខ្ញុំ។

ខាងក្រោមនេះ ជាសៀវភៅផ្សេងទៀតដែលខ្ញុំបានចេញផ្សាយរួចហើយ៖

សៀវភៅ ៤ឆ្នាំ

សៀវភៅ ចរិតឆ្កែ

សៀវភៅ រើសមកទុកវិញ

សៀវភៅ ជីវិតយើងខ្លីពេក

សៀវភៅ ជម្រើសទីពីរ

អ្នកទាំងអស់គ្នា អាចទិញសៀវភៅទាំងនេះ link នេះបាន

សូមអរគុណ។

ពីខ្ញុំ ហួត សេងគៀ

# អំពីអ្នកនិពន្ធ

ឈ្មោះ ហួត សេងគៀ។ ខ្ញុំជាអ្នកសរសេរសៀវភៅ ហើយក៏ចូលចិត្តអានសៀវភៅដែរ។ ខ្ញុំចំណាយពេលដែលសល់ពីការងាររបស់ខ្ញុំ ដើម្បីឆ្លៀតសរសេរសៀវភៅទាំងអស់របស់ខ្ញុំ។ ខ្ញុំមិនមានលទ្ធភាពបោះការងារចោលហើយសរសេរពេញម៉ោងនោះទេ។ ខ្ញុំក៏មិនភ្លើទៅធ្វើបែបនេះដែរ ព្រោះបើខ្ញុំធ្វើបែបនេះមែន ស្មើនឹងបញ្ចប់ការសរសេររបស់ខ្លួនឯងហើយ។

ឥលូវនេះខ្ញុំធ្វើការផ្នែកក្រាហ្វិចឌីហ្សាញ និង e-Learning នៅក្នុងក្រុមហ៊ុនបរទេសមួយ។ ខ្ញុំមិនមែនជាអ្នកជំនាញទេ។ ខ្ញុំរៀនបណ្ដើរធ្វើការបណ្ដើរប៉ុណ្ណោះ។ ខ្ញុំស្អប់សាលារៀន តែចូលចិត្តការរៀនដោយខ្លួនឯង ដូច្នេះការងារក្នុងផ្នែកនេះត្រូវជាមួយនឹងខ្ញុំណាស់។

ខ្ញុំមិនជឿលើសាសនា នយោបាយ ឬការឃោសនាអ្វីទាំងអស់។ ខ្ញុំជឿលើខ្លួនឯង ជឿលើធម្មជាតិ ជឿលើជីវិតសត្វ និងជឿលើភាពជាមនុស្ស។ ខ្ញុំមិនចូលចិត្តអ្នកណាមកនិយាយប៉ះនឹងជំនឿរបស់ខ្ញុំ។ មិនថាមានសក់ឬអត់សក់ សក់ខ្មៅ ឬសក់ស សក់វែង ឬសក់ខ្លីទេ ខ្ញុំមិនទុកមុខឱ្យទាំងអស់ បើនិយាយភ្លើដាក់ខ្ញុំ។ ខ្ញុំមិនចូលចិត្តមនុស្សភ្លើទេ។ ខ្ញុំជឿថា មនុស្សមានខួរក្បាល ដូច្នេះគួរតែប្រើវាឱ្យបានច្រើន ជាពិសេសមុននឹងនិយាយ ឬធ្វើអ្វីមួយទៅកាន់អ្នកដទៃ។

ខ្ញុំជាមនុស្សដែលងាយចុះសម្រុងនឹងគេណាស់ ពេលដែលខ្ញុំបិទមាត់ តែពេលណាខ្ញុំបញ្ចេញយោបល់ទៅ អ្នកដទៃនឹងដើរចេញមិនខាន។ ខ្ញុំមិនចូលចិត្តធ្វើពុត ឬនិយាយយកគួរទេ។ ខ្ញុំចូលចិត្តនិយាយចំៗ និងនិយាយចំមុខមនុស្សដែលត្រូវនិយាយទៀតផង។ ខ្ញុំមិនចូលចិត្តធ្វើអីឱ្យតែល្អមើលនោះទេ ខ្ញុំចង់ឃើញប្រយោជន៍របស់វា។

ខ្ញុំមិនមែនជាមនុស្សត្រឹមត្រូវតាមអ្វីដែលសង្គមចង់បាននោះទេ ព្រោះខ្ញុំមិនគោរពអ្វីដែលគេដាក់មកទេ។ ខ្ញុំមានគោលការណ៍របស់ខ្ញុំ ហើយខ្ញុំមិនខ្វល់ពីអ្វីដែលអ្នកដទៃនិយាយទេ។ ខ្ញុំជាមនុស្សឈ្លើយដែរពេលខ្លះ ព្រោះខ្ញុំមិនចង់ឱ្យគេដើរខ្សែលើខ្ញុំរហូតពេក។

អ្វីដែលអ្នកទាំងអស់អាននៅក្នុងសៀវភៅ គឺជាចរិតរបស់ខ្ញុំនៅខាងក្រៅហើយ។ បើធ្វើការប្រៀបធៀបសៀវភៅដែលខ្ញុំសរសេរពីមុន ចរិតខ្ញុំមានការផ្លាស់ប្តូរច្រើនណាស់។